# ជំពូក ៦

# អាណាចក្រភ្នំ

## ក. គ្រាដំបូងនៃអាណាចក្រភ្នំ

### ១. បញ្ហាឈ្មោះស្រុក

នៅខាងដើមគ្រិស្តសករាជ រដ្ឋដែលសំខាន់ជាងគេនៅអាស៊ីអគ្នេយ៍គឺ **អាណាចក្រភ្នំ** ។ ចិនហៅថា **ហ្វូណន** ។ ពាក្យ **ហ្វូណន**នេះចិនបូរាណអានថា **ប៊ីយូណាម**ដែលជាពាក្យគ្មានន័យអ្វីអោយប្រាដកក្នុងភាសាចិនទេ ។ ដោយហេតុនេះហើយបានជាអ្នកសិក្សាស្រាវជ្រាវ បានព្យាយាមរាវរកមើលថា តើពាក្យ **ហ្វូណន**នេះត្រូវនឹងពាក្យអ្នកស្រុកអាយថាម៉េច ?

- មានមតិខ្លះចាត់ទុកថា **ហ្វូណន**ត្រូវនឹងពាក្យខ្មែរថា **ត្នោត**ដោយសំអាងថាកុលសម្ព័ន្ធភ្នងដែលរស់នៅលើខ្ពង់រាបសព្វថ្ងៃ ស្ថិតនៅក្នុងអំបូរជាមួយខ្មែរនេះម្យ៉ាង ហើយម្យ៉ាងទៀតដោយសំអាងថារូបចម្លាក់ នៅលើជញ្ជាំងប្រាសាទបូរាណខ្មែរ បានបង្ហាញថាខ្មែរក្នុងសម័យនោះ មានសំលៀកបំពាក់ និងទម្លាប់ខ្លះដូចពួកភ្នងដែរ ។ ចំពោះរឿងនេះគួរកត់សំគាល់ថាលោកសាស្ត្រាចារ្យ L. Brumpt បានបញ្ជាក់ថា ខ្មែរ និងភ្នងពិតជាមានពូជអំបូរជាមួយគ្នាមែន ដោយសំអាងទៅលើលទ្ធផលនៃការសិក្សារបស់លោកទៅលើឈាមក្រហម (hémoglobines)(23) ។

- ចំណែកលោក G. Coedès លោកយល់ថា **ហ្វូណន** ត្រូវនឹងពាក្យខ្មែរបុរាណ **វ្នំ** ដែលសព្វថ្ងៃក្លាយជា **ភ្នំ** ។ លោកបានបញ្ជាក់ថា ស្តេចនៅសម័យនោះមានឋានន្តរនាមថា **ស្តេចភ្នំ** ពាក្យខ្មែរបូរាណថា **កុរុងវ្នំ** ត្រូវនឹងសំស្ក្រឹតថា **បវិតភូបាល** ឬ **សៃលរាជ** ។ ជនជាតិចិនក៏បានយកឋានន្តរនាមនេះប្រើសំរាប់ ហៅប្រទេសដែលស្តេចទាំងនោះគ្រប់គ្រងផងដែរ ។

ចំពោះទម្លាប់ខាងលើនេះ លោក E. Aymomier បានកត់សំគាល់ឃើញថា ក្នុងសម័យបូរាណចិនមិនចេះវែកញែកមនុស្សអោយដាច់ពីប្រទេសទេ ។ ពួកនេះច្រើនប្រើឈ្មោះតែមួយសំរាប់សំគាល់មនុស្សផងរាជធានីផងប្រទេសទាំងមូលផង ឬ ក៏ឈ្មោះឋានន្តរនាមរបស់អ្នកដឹកនាំផង(24) ។

ចំពោះទស្សនៈរបស់លោក G . Coedès នេះ គួរកត់សំគាល់ថា ឯកសារចិនបាននិយាយច្បាស់ថា អធិរាជអាណាចក្រភ្នំមានឋានន្តរនាម **គូឡុងគី ក្រុង** ដែលសព្វថ្ងៃមានន័យថា **ស្តេចសោយរាជ្យ** ។ បើដូច្នេះ ពាក្យ **ហ្វូណន** ចិនហៅតាមឋានន្តរនាមរបស់អធិរាជអាណាចក្រភ្នំគឺ **គុរុងភ្នំ**នេះឯង ។ ឯការដែលមានឋានន្តរនាមយ៉ាងនេះគឺប្រហែលមកពីភ្នំជាទីកន្លែងដែលអធិរាជឡើងទៅជួបនឹងព្រះឥសូរៈ ឯកសារចិនបាននិយាយថា " ព្រះអាទិទេពយាងចុះលើភ្នំម៉ូតាន់(Mo -tan) ជាញឹកញាប់ ព្រះអង្គបានមកទីនោះដើម្បីបញ្ចេញមហិទ្ធិរិទ្ធិរបស់ព្រះអង្គ ព្រះអធិរាជទាំងឡាយបានទទួលនូវពរជ័យពីព្រះអង្គ ហើយប្រជារាស្ត្រក៏បានសុខចំរើនដោយសារនោះផង " ។

## ២. បញ្ហាទីតាំង

នៅមុនពេលសង្គ្រាមសកលលោកលើកទី១ គេឃើញមានកង្វែងយោបល់ច្រើនចំពោះទីតាំងរបស់អាណាចក្រភ្នំ ។ ចំពោះលោក wilford លោកយល់ថារដ្ឋហ្វូណនស្ថិតនៅត្រង់ប្រទេសម៉ាឡេស៊ី ។ លោកA. Rémusat ជឿថា ហ្វូណនជាអាណាចក្រខេត្តមួយរបស់ចិន ហើយស្ថិតនៅត្រង់ប្រទេសតុងកឹង ។ លោក klaproth និង Pauthier ថា ហ្វូណនត្រូវនឹងដែនដី pégou និងប្រទេសភូមា ។ លោក Dequines ថាត្រូវនឹងកោះមួយនៅខាងលិចប្រទេសសៀម ។ ឯលោក Barth ថាត្រូវនឹងឆ្នេរសមុទ្រតេណាស្សេរីម ក្រៅពីនេះ អ្នកសិក្សាឯទៀតជឿថា ហ្វូណននៅត្រង់ប្រទេសខ្មែរ ឬប្រទេសសៀម ។

ដើម្បីអោយដឹងច្បាស់ពីទីតាំងរបស់ហ្វូណន គួរគប្បីយើងលើកយកឯកសារចិនមកពិនិត្យអោយបានហ្មត់ចត់សិន ។ ឯកសារទាំងនោះបានផ្តល់ពត៌មានសំខាន់ៗដូចតទៅ :

១ - ហ្វូណនមានចម្ងាយ ៣០០០លី ខាងលិចប្រទេសលីនយី

២ - ហ្វូណនមានចម្ងាយ ៧០០០លីពី Jenan (តុងកឹង)

៣ - ហ្វូណនមានទំហំ ៣០០០លី ក្រោយពង្រីកធំដល់ ៥០០០ ឬ ៦០០០លី

៤ - ហ្វូណនស្ថិតនៅក្នុងឈូងសមុទ្រធំមួយ

៥ - មានទន្លេធំមួយហូរពីខាងលិច (ឯកសារខ្លះថាពាយព្យ) ហើយចាក់ទៅសមុទ្រ ។

ប្រសិនបើយើងគិតថា១ លីមានប្រវែង៥៧៦ មែត្រចម្ងាយពីលីនយីមកហ្វូណនមាន១៧២៨ គ.ម. គឺត្រូវនឹងប្រទេសខ្មែរសព្វថ្ងៃ កម្ពុជាក្រោមនិងប្រទេសថៃផ្នែកកណ្តាល ។ ឈូងសមុទ្រធំក្នុងឯកសារ

ចិនគឺជាឈូងសមុទ្រថៃ ឯទន្លេធំដែលហូរចាក់ទៅក្នុងសមុទ្រ គឺគ្មានអ្វីក្រៅពីទន្លេមេគង្គឬ បើនិយាយអោយចំទៅ គឺទន្លេសាបហ្នឹងឯង ។ សរុបសេចក្តីមកឃើញថាមជ្ឈមណ្ឌលរបស់ហ្វូណន ស្ថិតនៅត្រង់វាលទំនាបខាងក្រោមនៃទន្លេមេគង្គនេះឯង ។ ត្រង់នេះអ្នកសិក្សាហាក់ដូចជាយល់ស្របគ្នា ហើយតែនៅមានចំណុចមួយទៀតដែលអ្នកសិក្សានៅមិនទាន់ហ៊ានអារកាត់នៅឡើយ គឺរឿងទីតាំងនៃរាជធានីដំបូងរបស់ហ្វូណន ។

យ៉ាងណាមិញ សិលាចារឹកខ្មែរសម័យក្រោយមកទៀតបាននិយាយពីក្រុង **វ្យាធបុរ** (បុរីនៃស្តេចទាក់ដំរី)ដែលអ្នកប្រវត្តិសាស្ត្របានចាត់ទុកថា ជារាជធានីមួយរបស់ហ្វូណន ។ ចិនហៅរាជធានីហ្វូណនថា **តូម៉ូ** (T´o - mou) ដែលលោក G. Coedès ថាត្រូវនឹងពាក្យខ្មែរបុរាណ **ធ្នាក់ឬ ឧល្នាក់** (អ្នកទាក់ដំរី) ។ លោកយល់ទៀតថា ក្រុងវ្យាធបុរនេះស្ថិតនៅម្តុំបាភ្នំនិងបាណាមក្នុងខេត្តព្រៃវែងសព្វថ្ងៃ ។ ព្រះភិក្ខុប៉ាង ខាត់ក៏មានព្រះយោបល់ដូច្នេះដែរ ។ ព្រះអង្គបានសរសេរថា :"រាជធានីវ្យាធបុរ តាំងនៅតំបន់បាភ្នំទំនងជានៅភ្នំខ្សាច់បច្ចុប្បន្ននេះ ព្រោះគេបានរកឃើញបុរាណដ្ឋាននិងបុរាណទេវរូបជាច្រើន នៅទីនោះ ។ សិលាចារឹកមួយនៅវត្តចក្រឹតនៅជើងភ្នំ ពី ស.វ. ទី១០ បាននិយាយពីការកសាងទេវរូបព្រះឥសូរហៅថា **អម្រិតវ្យាធបុរេស្វរ** តំកល់ទុកនៅទីនោះ "(25) ។ គួរកត់សំគាល់ម្យ៉ាងទៀតថា នៅតំបន់បាភ្នំឈើកាច់សព្វថ្ងៃនេះមានភូមិជាច្រើនដែលមានឈ្មោះទាក់ទងនឹងដំរី គឺភូមិ **រោងដំរី ក្បាលដំរី** និង **ព្រៃដំរី** ។ តើយើងអាចចាត់ទុកឈ្មោះទាំងនេះថា ជាអនុស្សាវរីយ៍រំលឹកទីតាំងរាជធានីអាណាចក្រភ្នំបានទេ ? តាមប្រវត្តិរាជវង្សលាង ក្រុងនេះស្ថិតនៅប្រហែល ២០០លីពីសមុទ្រ បើគិតទៅគឺត្រូវនឹងចម្ងាយពីបាភ្នំទៅ **អូកែវ** ដែលជាកំពង់ផែធំមួយរបស់ហ្វូណន ។ នៅពេលសង្គ្រាម លោកលើកទីពីរលោក Louis Malleret អ្នកប្រាជ្ញបារាំងបានធ្វើកំណាយផ្សេងៗក្នុងដែនដីសណ្តទន្លេមេគង្គ ហើយបានរកឃើញរមណីយដ្ឋាន **អូកែវ**នេះដែល លោកចាត់ទុកថាជាកំពង់ផែធំរបស់ហ្វូណន ព្រោះនៅទីនោះគឺនៅខាងត្បូងភ្នំបាថេ ខេត្តក្រមួនស គេបានជីករកឃើញយឿនសំណង់ផ្សេងៗព្រមទាំងវត្ថុផ្សេងទៀតជាច្រើនខ្លះមកពីចក្រភពរ៉ូម ខ្លះទៀតមកពីប្រទេសឥណ្ឌា និង ខ្លះទៀតជាវត្ថុធ្វើពីថ្មរំលីង ។ ដោយហេតុនេះហើយទើបមានមតិខ្លះចាត់ទុកថា អូកែវនេះជារាជធានីដើមបង្អស់របស់ហ្វូណន ។ ប៉ុន្តែមានអ្នកសិក្សាខ្លះទៀតដូចជាលោកJean Boisselier ជាដើម បែរជាយល់ថា រាជធានីនេះស្ថិតនៅត្រង់វាលទំនាបខាងក្រោមនៃទន្លេមេណាមវិញ ព្រោះលោកសំអាងថានៅទីនោះលោកបានរកឃើញរូបខ្លះធ្វើពីដីឥដ្ឋ ។ បើតាមលោក របស់បែបនេះគឺជារបស់ធ្វើក្នុងស្រុក មិនមែននាំយកមកពីក្រៅទេ ។ ប៉ុន្តែ អ្នកប្រាជ្ញបារាំងរូបនេះយល់ដែលថា នៅខាងចុងសម័យហ្វូណន រាជធានីនេះត្រូវលើកយកទៅតាំងត្រង់កន្លែងមួយ នៅជិតពាមទន្លេមេគង្គខាងត្បូងប្រទេសកម្ពុជា (26) ។

## ៣. បញ្ហាបង្កើតរាជវង្សដំបូង

លោក **តាំង ថៃ** រាជទូតចិនដែលបានធ្វើដំណើរមកហ្វូណននៅពាក់កណ្ដាលស.វ.ទី ៣បាន កត់ទុកថាបឋមក្សត្រនៃរដ្ឋហ្វូណនឈ្មោះ **ហ៊ុនទៀន** បានមកពីប្រទេសឥណ្ឌា ឬពីជ្រោយម៉ាឡាយូ ឬ ពីកោះខាងត្បូង ។ **ហ៊ុនទៀន** បានយល់សប្ដិឃើញទេវតាក្សាខ្លួនប្រគល់ធ្នូទិព្វអោយ ហើយបញ្ជា អោយឡើងជិះសំពៅដ៏ធំមួយ ។ ព្រលឹមឡើងហ៊ុនទៀនបានទៅកាន់ប្រាសាទតំកល់ទេវតា ហើយបាន ឃើញធ្នូដូចយល់សប្ដិមែន ។ បន្ទាប់ពីនោះក៏បានធ្វើដំណើរតាមសមុទ្រហើយទៅដល់ហ្វូណន ។ រាជិនីរដ្ឋនេះឈ្មោះនាង **លីវយី** លុះបានឃើញសំពៅចម្លែកក៏លើកទ័ពមកបំរុងដេញកំចាត់សត្រូវ តែត្រូវ **ហ៊ុនទៀន** យកធ្នូទិព្វបាញ់សំពៅរបស់នាងធ្លាយពីម្ខាងទៅម្ខាង ។ នាងភិតភ័យខ្លាំងហើយសំចុះ ចាញ់ **ហ៊ុនទៀន** ក៏យកនាងធ្វើជាមហេសី ។ រួចមកក៏នៅគ្រប់គ្រងរដ្ឋហ្វូណនជាតំណតទៅកូនទៅ ចៅទៀតផង ។

នេះជារបៀបនិទានរឿង ( version) របស់ចិនស្ដីអំពីដើមកំណើតនៃរាជវង្សនៅហ្វូណន ។ ចំណែកសិលាចារឹកចាមនៅមីសឺន(គ.ស.៦៥៨)(27) បានរំលឹកពីដើមកំណើតនេះដោយនិទានថា ព្រាហ្មណ៍ **កៅណ្ឌិន្យ** ដែលបានទទួលលំពែងមួយពីព្រាហ្មណ៍ **អស្វត្ថាម៉ន** បានពួយលំពែងនោះ ដើម្បី រកកន្លែងកសាងរាជធានី រួចបានរៀបរាជាភិសេកជាមួយនាង **សោមា** ជាបុត្រីរបស់ស្ដេចភុជង្គនាគ ដែលបានបង្កើតរាជវង្សមួយគឺសោមវង្ស ។ គួរកត់សំគាល់ថារឿងបែបនេះត្រូវបានសិលាចារឹកខ្មែរ មួយនៅស.វ.ទី១០(សិលាចារឹកបក្សីចាំក្រុង)រំលឹកឡើងវិញ ហើយបើតាមគេប៉ាន់ស្មានមើលទៅគឺត្រូវ នឹងរឿងដែល លោកជីវតាក្វាន់បានកត់ទុក កាលបានមកទស្សនាប្រទេសខ្មែរនៅសម័យអង្គរ (ចុង ស.វ.១៣)និងត្រូវនឹងរឿង **ព្រះថោង នាងនាគ** ក្នុងរាជពង្សាវតារខ្មែរយើងទៀតដែរ ។

ដូច្នេះ ទោះបីរបៀបនិទានរឿងមានសភាពប្លែកៗគ្នាក៏ដោយក៏យើងអាចសន្និដ្ឋានបានថាតួអង្គ **ហ៊ុនទៀនឬកៅណ្ឌិន្យ** ឬ **ព្រះថោង** ជាមនុស្សតែម្នាក់ ឯនាង **លីវយី** ក៏ដូចគ្នានឹង **សោមា** ឬ **នាង នាគ**ដែរ ។ ហើយទោះបីរឿងទាំងនេះមានលក្ខណៈជារឿងព្រេងក៏ដោយ ក៏អាចបង្ហាញការពិត ដល់ យើងខ្លះមិនខានៈគឺថាមានជាតុបរទេសមួយគឺជាតុឥណ្ឌាបាននាំអរិយធម៌របស់ខ្លួនមកផ្គុំផ្សំជាមួយ និង អរិយធម៌របស់អ្នកស្រុកអាយ (មាននាងនាគជាតំណាង) ដើម្បីបង្កើតអរិយធម៌ចំរុះមួយដែលបានវិវត្ត រហូតដល់សព្វថ្ងៃនេះ ។ ម្យ៉ាងទៀតព្រឹត្តិការណ៍ទាំងនេះ ត្រូវតែបានកើតឡើងក្នុងគ្រិស្តសតវត្សទី១ ព្រោះថានៅសតវត្សបន្ទាប់មកទៀត ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រត្រូវបានកត់ត្រាដោយសិលាចារឹកផងនិង ដោយអ្នកប្រវត្តិសាស្ត្រចិនផង ។

បើតាមពង្សាវតាររាជវង្សលាង ហ៊ុនទៀនមានបុត្រម្នាក់ដែលបានទៅត្រួតត្រាលើទឹកដីមួយផ្នែកដែលមានក្រុងប្រាំពីរ ។ ក្នុងចំណោមអ្នកសោយរាជ្យតមកមានស្តេចឈ្មោះ**ហ៊ុនផានហួង** ។ ស្តេចអង្គនេះបានប្រើឧបាយកលផ្សេងៗដើម្បីអោយក្រុងទាំងនោះបែកបាក់សាមគ្គីគ្នាអស់ រួចទៅលើកទ័ពទៅវាយយកបានទាំងអស់ ។ បន្ទាប់មកបានចាត់អោយកូននិងចៅរបស់ព្រះអង្គទៅត្រួតត្រាក្រុងទាំងនោះ មួយម្នាក់ៗ ។ ស្តេច **ហួនផានហួង** សោយទីវង្គតនៅពេលដែលមានជន្មាយុជាង៩០ឆ្នាំ ។ បុត្រទី ២ឈ្មោះ **ផានផាន** ត្រូវលើកអោយឡើងសោយរាជ្យ តែបានប្រគល់កិច្ចការរដ្ឋទាំងឡាយអោយមេទ័ព **ហ្វានចេម៉ាន់** មើលខុសត្រូវ ។ ស្តេច **ផានផាន** សោយរាជ្យបានតែ ៣ឆ្នាំក៏សុគតទៅ ។ ប្រជារាស្ត្របានព្រមព្រៀងគ្នាលើកអោយ **ហ្វានចេម៉ាន់** ឡើងសោយរាជ្យ ។ ស្តេចអង្គនេះមានសេចក្តីក្លាហាន ហើយមានឫទ្ធានុភាពខ្លាំងណាស់ ព្រះអង្គបានលើកទ័ពទៅវាយយកប្រទេសជិតខាងដាក់ជាចំនុះអស់ជាច្រើន ។ ព្រះអង្គទ្រង់ប្រកាសថាជា "**មហារាជនៃហ្វូណន** " ។ បន្ទាប់មកទ្រង់បញ្ជាអោយធ្វើសំពៅធំៗជិះកាត់សមុទ្រទៅវាយបាននគរជាង១០ ដែលក្នុងចំណោមនោះមាននគរ **គីវទូគុន** (k'iu-tou-k'ouen) **កៀវឆេ** (Kieou-tche) **ទៀន ស៊ុន** (Tien- Souen ) ។ ព្រះអង្គបានពង្រីកទឹកដីធំរហូតដល់ ៥ ឬ ៦ ពាន់លី ។

អ្នកប្រវត្តិសាស្ត្រនិយមចាត់ទុកដោយសមហេតុសមផលថា **ហ្វានចេម៉ាន់** នេះត្រូវនឹងស្តេច **ស្រីមារះ** ដែលមានឈ្មោះចារនៅក្នុងសិលាចារឹកវ៉ូកាញ់(ខេត្តញ៉ាត្រាង-ប្រទេសវៀតណាមសព្វថ្ងៃ ) ដែលពីដើមគេយល់ច្រឡំថាជារបស់ចាម្ប៉ា តែក្រោយមក គឺចាប់ពីគ.ស.១៩២៧ លោកLouis Finot ចាត់ទុកថាជារបស់សាមន្តរដ្ឋមួយរបស់អាណាច្រកភ្នំទៅវិញ ។

ឯកសារចិនបានបញ្ជាក់ប្រាប់យើងជាបន្តទៅទៀតថាស្តេច **ហ្វានចេម៉ាន់** បានសោយទីវង្គតនៅពេលលើកទ័ពទៅវាយរដ្ឋ " **គីនលីន** "(កំពែងមាស)ដែលលោក G . Coedès ថាត្រូវនឹង **សុវណ្ណភូមិ** (ដីមាសក្នុងអត្ថបទបាលី)ឬ**សុវណ្ណកុដ្យ** (កំពែងមាសក្នុងអត្ថបទសំស្ក្រឹត.នៅប្រទេសភូមាខាងត្បូង ឬលើជ្រោយម៉ាឡាយូ) ។ នៅពេលដែលទ្រង់ប្រឈួន **ហ្វាន់ចេម៉ាន់** ទ្រង់បានបញ្ជូនរាជបុត្រឈ្មោះ **គិនចេង** អោយទៅសោយរាជ្យជាជំនួសព្រះអង្គ ។ ពេលនោះ ក្មួយព្រះអង្គឈ្មោះ **ឆាន** (កូននៃបងស្រីរបស់ព្រះអង្គ)ដែលជាមេត្រួតទ័ព២០០០នាក់ ក៏បានជ្រែករាជ្យដោយបានធ្វើគត់រាជទាយាទ**គិនចេង** ។ ពេលដែលព្រះអង្គសោយទីវង្គតទៅ **ហ្វានចេម៉ាន់** មានបុត្រមួយទៀតដែលនៅបៅដោះនៅឡើយ ។ បុត្រនេះឈ្មោះ **ឆាង** ហើយរស់នៅក្នុងចំណោមប្រជារាស្ត្រ ។ លុះធំឡើងបានព្រះជន្ម២០វស្សាហើយ បុត្រអង្គនេះបានប្រមូលបក្សពួកលើកទៅសម្លាប់ស្តេច **ឆាន** បាន ។ ប៉ុន្តែមេទ័ពរបស់ **ឆាន**ឈ្មោះ **ហ្វានស៊ីយុន**បានធ្វើគត់ **ឆាង**វិញបានរួចឡើងសោយរាជ្យ ។ព្រះអង្គទ្រង់បានបញ្ជាអោយកសាងកន្លែងផ្សេងៗសំរាប់ទ្រង់ទៅកំសាន្ត ។ ពេលព្រឹកនិងពេលថ្ងៃត្រង់ ព្រះអង្គទ្រង់ប្រទានសវនាការ ៣ឬ៤ដង ។ ជនបរទេសនិងប្រជារាស្ត្របានយកជង្វាយផ្សេងៗមកថ្វាយ មានចេក អំពៅអណ្តើក និងសត្វបក្សី... ។

ព្រឹត្តិការណ៍ទាំងប៉ុន្មានខាងលើចាប់ពី **ហ្វានចេម៉ាន**សោយទីវង្គតដល់**ហ្វានស៊ីយុន**ឡើងសោយរាជ្យ បានកើតឡើងនៅចន្លោះឆ្នាំ ២២៥និង២៥០ ។ គឺនៅចន្លោះកាលកំណត់ទាំងពីរនេះហើយ ក្នុងរជ្ជកាលរបស់ **ហ្វានឆាន** ដែលអាណាចក្រភ្នំបានទាក់ទងជាលើកដំបូងជាមួយនិងរាជវង្ស **មុរុណ្ឌ**នៅប្រទេសឥណ្ឌានិងបានបញ្ជូនរាជទូតទី១ទៅកាន់ប្រទេសចិន ។ ចំពោះទំនាក់ទំនងជាមួយចិនខាងលើនេះលោក G. Coedès យល់ថាជារឿងមានលក្ខណៈពាណិជ្ជកម្មច្រើនជាងលក្ខណៈនយោបាយ ។ យ៉ាងណាមិញនៅសម័យនោះគឺសម័យរាជាអាណាចក្របី-ប្រទេសចិនខាងត្បូង(រាជាអាណាចក្រវូ)ដែលមិនអាចធ្វើជំនួញជាមួយបស្ចិមប្រទេសតាមផ្លូវគោក(កាន់កាប់ដោយពួកវ៉ី) ក៏បែរមករកទិញវត្ថុប្រណិតដែលខ្លួនត្រូវការតាមផ្លូវសមុទ្រវិញ ។ ដោយហេតុនេះហើយបានជាគេមកទាក់ទងជាមួយអាណាចក្រភ្នំដែលស្ថិតនៅចំផ្លូវទៅមកនៃជំនួញខាងសមុទ្រហើយដែលជាតំណាក់មួយជៀសវាងមិនបានសំរាប់អ្នកដើរសំពៅឆ្លងកាត់តាមច្រកម៉ាឡាក់កាឬអ្នកចូលចិត្តដឹកទំនិញឆ្លងចុះឡើងតាមបួរដីនៃជ្រោយម៉ាឡាយូ ។

ចំពោះទំនាក់ទំនងជាមួយឥណ្ឌាវិញ ឯកសារចិនមួយនៅចុងសតវត្សទី៥ បាននិយាយថាមានមនុស្សម្នាក់ឈ្មោះ **គៀសៀងលី** ជាមនុស្សនៃស្រុក **តាន់យ៉ាង**(នៅខាងលិចប្រទេសឥណ្ឌា) បានធ្វើដំណើរទៅប្រទេសឥណ្ឌា រួចបង្ហួសមកអាណាចក្រភ្នំ ។ គឺជននេះហើយដែលបាននិយាយប្រាប់ **ហ្វានឆាន** ពីរឿងប្លែកៗនៅប្រទេសឥណ្ឌា ប៉ុន្តែដំណើរទៅកាន់ប្រទេសនោះត្រូវអស់ពេលយូរៈ ទាំងទៅទាំងមកអស់ ៣ឆ្នាំឬដល់៤ឆ្នាំក៏សឹងមាន ។ គេដឹងច្បាស់ថាស្តេច **ហ្វានឆាន**ប្រហែលជក់ចិត្តនឹងរឿងចំឡែកអស់ទាំងនោះហើយបានបញ្ជូនញាតិរបស់ព្រះអង្គឈ្មោះ **ស៊ូវូ**ជាទូតទៅកាន់ប្រទេសឥណ្ឌា ។ រាជទូតរូបនេះបានចុះសំពៅទៅ **តូចគីវលី** (T'eou -kiu-li) ប្រហែលត្រូវនឹងតក្កោលត្រង់នេះ សអោយឃើញថា អាណាចក្រភ្នំលាតសន្ធឹងឥទ្ធិពលទៅដល់មហាសមុទ្រឥណ្ឌា ។ រាជទូតអាណាចក្រភ្នំបានទៅដល់ពាមទន្លេគង្គា រួចធ្វើដំណើរតាមដងទន្លេឡើងទៅដល់រាជធានីរបស់ស្តេចមួយអង្គ ដែលលោក S. Lévi ថា ជាស្តេចក្នុងរាជវង្ស **មុរុណ្ឌ** ។ ស្តេចអង្គនេះនាំភ្ញៀវអោយដើរទស្សនាប្រទេសព្រះអង្គ រួចអោយឥណ្ឌាម្នាក់ឈ្មោះ **ឆេន សុង**នាំត្រឡប់មកវិញដោយប្រគល់អោយសេះ៤នៃស្រុកនោះ ដើម្បីទុកជាជង្វាយនៃព្រះអធិរាជអាណាចក្រភ្នំផង ។

បើតាមពង្សាវតារនៃអាណាចក្របី គឺស្តេច **ហ្វានឆាន** ដដែលនេះហើយដែលបានបញ្ជូនទូតទី១ទៅកាន់ប្រទេសចិននៅគ.ស.២៤៣ដើម្បីនាំជង្វាយជាអ្នកភ្លេងនិងផលិតផលផ្សេងៗទៅថ្វាយស្តេចក្រុងចិន ។

គេអាចចោទសួរម្យ៉ាងទៀតថា តើស្តេច **ហ្វានឆាន**នេះដែរឬដែលជាអ្នកនិពន្ធសិលាចារឹកវ៉ូកាញ់ដែលបានចាត់ទុកព្រះអង្គថាជាញាតិរបស់ព្រះបាទ **ស្រីមារៈ** ?

ស្តេច **ហ្វានស៊ីយុន**ដែលបានសោយរាជ្យតពី **ហ្វានឆាន**ក្រោយពីបានធ្វើគត់បុត្រមួយអង្គរបស់ **ហ្វាន់ចេម៉ាន់** បានទទួលនៅប្រមាណគ.ស.២៤៥-២៥០នូវគណៈបេសកកម្មទូតរបស់លោក **ភាំងថៃ** និងលោក **ឈុយីខ** ដែលបានមកជួបគ្នាជាមួយនឹងទូតឥណ្ឌានៅក្នុងរាជវាំង ។ គណៈបេសកកម្មទូតនេះ បានមកចងស្ពានមេត្រីជាមួយអាណាចក្រភ្នំ ។ បន្ទាប់ពីនោះគេឃើញស្តេច**ហ្វានស៊ីយុន** បញ្ជូនទូតទៅ ប្រទេសចិនជាច្រើនលើកនៅចន្លោះគ.ស.២៦៨ដល់ ២៨៧ហើយដែលមានកត់ទុកក្នុងពង្សាវតាររាជ វង្សស៊ីន ។ តាមគេប៉ាន់ស្មានមើលទៅការបញ្ជូនទូតបីលើកចុងក្រោយគឺពី គ.ស.២៨៥ដល់២៨៧ ប្រហែលជាផលវិបាកនៃការមានសន្ទុះឡើងវិញក្នុងផ្នែកជំនួញផ្លូវសមុទ្រ ក្រោយពីការធ្វើអោយ ប្រទេសចិនមានឯកភាពឡើងវិញដោយរាជវង្សស៊ីន ព្រោះព្រឹត្តិការណ៍នេះបណ្តាលអោយមានសេចក្តី ត្រូវការនូវវត្ថុប្រណីតយ៉ាងខ្លាំងពីសំណាក់ពួកស្តេច ។

## ខ. អាណាចក្រភ្នំពី គ.ស.៣៥៧ដល់ការវាយលុករបស់ចេនឡា

ស្តេច **ហ្វានស៊ីយុន** បានសោយរាជ្យដល់គ.ស.២៨៩ ។ ពីនេះដល់ពាក់កណ្តាលស.វ.ទី៤គ្មាន ឯកសារណានិយាយពីអាណាចក្រភ្នំសោះ ។ ពង្សាវតាររាជវង្សស៊ីន និង លាង បាននិយាយថានៅ គ.ស.៣៥៧ ស្តេចអាណាចក្រភ្នំឈ្មោះ **ចៀនឈូ ឆានតាន**បានលើកសួយជាដំរីផ្សាំងទៅថ្វាយស្តេច ក្រុងចិន ។ **ចៀនឈូ** គឺឈ្មោះដែលចិនហៅប្រទេសឥណ្ឌា ។ ដូច្នេះពាក្យថា **ចៀនឈូ - ឆានតាន** បានន័យថា ឥណ្ឌាឈ្មោះ "**ឆានតាន** " ។ បើតាមលោកS.Lévi **ឆានតាន** គឺជាពាក្យកត់សំលេង chandan ដែលមានឋានន្តរនាមរបស់ពួកឥណ្ឌូ-ស៊ីថ ជាពិសេសរបស់រាជវង្ស**គុសាណះ** ។ គួរគប្បី បញ្ជាក់ថា ពួក **គុសាណះ**នេះបានលើកទ័ពចូលវាយប្រទេសឥណ្ឌា ហើយត្រួតត្រាតំបន់ទន្លេគង្គា យ៉ាង ហោចរហូតដល់ក្រុងពារាណសី ។ នៅគ.ស.៣៥៧ ប្រទេសឥណ្ឌាភាគខាងជើងទាំងមូលត្រូវធ្លាក់នៅ ក្រោមការគ្រប់គ្រងរបស់រាជវង្ស **គុប្ត** ក្រោមកិច្ចដឹកនាំរបស់ព្រះចៅ **សមុទ្រគុប្ត** ។ ដូច្នេះពួកស៊ីថ ឈ្លានពានក៏ត្រូវកំចាត់ចេញ ។ គឺប្រហែលជាក្នុងកាលៈទេសៈបែបនេះហើយដែលមានពួក **គុសាណះ** បានភៀសខ្លួនមកកាន់សុវណ្ណភូមិ ហើយជាពិសេសមកកាន់អាណាចក្រភ្នំ ដូចករណីរបស់ស្តេច **ចៀន ឈូ ឆានតាន** នេះឯង ។ អ្នកសិក្សាយល់ថា ប្រហែលជាស្តេចអង្គនេះហើយដែលបាននាំមក អោយ អាណាចក្រភ្នំនូវធាតុសំខាន់ៗខ្លះក្នុងផ្នែកសិល្បៈចម្លាក់ដូចជាអាវផាយរបស់ព្រះសូរ្យ និងមកុដរាងបំពង់ របស់ព្រះវិស្ណុ ។ ការបញ្ចេញយោបល់បែបនេះគឺបានសំអាងមួយផ្នែកទៀតទៅលើរបស់ខ្លះ ដែលគេ បានរកឃើញនៅរមណីយដ្ឋានអូកែវ ហើយដែលជាភស្តុតាងបង្ហាញពីទំនាក់ទំនងរវាងអាណាចក្រភ្នំ និងពិភពអ៊ីរ៉ង់ ដូចជាដុំថ្មឆ្លាក់រូបពិធីបួងសួងចំពោះព្រះអគ្គី និងដុំពេជ្រមានរូបស្តេចនៃរាជវង្ស សាស្សានីដ (Sassanide) ។

ចំពោះរជ្ជកាលស្តេច **ឆៀនឈុ ឆានតាន**នេះព្រឹត្តិការណ៍ដែលគេបានដឹងច្បាស់មានតែមួយ គឺការលើកសួយទៅថ្វាយស្តេចក្រុងចិននៅគ.ស.៣៥៧នោះឯង ។ ក្រោយពីនោះ អ្នកប្រវត្តិសាស្ត្រត្រូវជួបប្រទះនឹងកង្វះឯកសារជាថ្មីម្តងទៀត ហើយពត៌មានស្តីពីអាណាចក្រភ្នំ គេនឹងអាចដឹងបានតែចាប់ពីចុងស.វ.ទី៤ទៅប៉ុណ្ណោះ ។

នៅពាក់កណ្តាលទី១នៃស.វ.ទី៥គេបានសង្កេតឃើញថាចលនាផ្សព្វផ្សាយអរិយធម៌ឥណ្ឌានៅតំបន់សុវណ្ណភូមិមានកម្លាំងរឹតតែខ្លាំងក្លាលើសដើម ។ អ្នកប្រវត្តិសាស្ត្របានខិតខំរកមើលថាតើអ្វីទៅជាមូលហេតុនៃរឿងនេះ ។ តាមគេប៉ាន់ស្មានមើលទៅការវាយលុករបស់ព្រះបាទសមុទ្រគុប្ត(៣៣៥-៣៧៥)នៅក្នុងប្រទេសឥណ្ឌាភាគខាងត្បូង ប្រហែលជាបានបណ្តាលអោយមានពួកអភិជនភៀសខ្លួនមកកាន់បូព៌ាប្រទេស ។ រួចមកហើយ យើងបានឃើញថាលោក S. Lévi បានចាត់ទុកថាគឺការវាយលុករបស់ព្រះបាទ **សមុទ្រគុប្ត** ដដែលនេះនៅតំបន់វាលទំនាបទន្លេគង្គាដែលបណ្តាលអោយមានជនជាតិស៊ីថម្នាក់មកសោយរាជ្យនៅអាណាចក្រភ្នំនៅគ.ស.៣៥៧ ។ បើតាមមើលទៅព្រឹត្តិការណ៍នេះគ្រាន់តែជាជំហានដំបូងនៃចលនាទូលំទូលាយមួយដែលបាននាំមកកាន់តំបន់ដែលបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាស្រាប់ទៅហើយនូវពួកស្តេច ពួកព្រាហ្មណ៍ និងពួកបញ្ញាវន្តចាប់ពីកណ្តាលស.វ.ទី៤ដល់កណ្តាលស.វ.ទី ៥ ។

គឺនៅក្នុងពេលជាមួយគ្នានេះនិងដោយមានមូលហេតុដូចគ្នានេះដែរ ដែលអាណាចក្រភ្នំបានទទួលនូវសន្ទុះថ្មីមួយនៃការផ្សាយអរិយធម៌ឥណ្ឌា ។

រាជពង្សាវតារចិនបានកត់ទុកថា ក្នុងចំណោមស្តេចដែលសោយរាជ្យតៗមកពី **ឆៀន ឈុឆាន-តាន** មានស្តេចមួយអង្គឈ្មោះ **គាច នៃនយូ** (កៅណ្ឌិន្យ)ជាព្រាហ្មណ៍មានដើមកំណើតនៅប្រទេសឥណ្ឌា ។ គេដំណាលថាមានសម្លេងអាថ៌កំបាំងមួយ បានបញ្ជាអោយព្រាហ្មណ៍នេះទៅសោយរាជ្យ នៅអាណាចក្រភ្នំ ។ **កៅណ្ឌិន្យ**មានសេចក្តីរីករាយយ៉ាងខ្លាំងហើយបានធ្វើដំណើរទៅដល់ស្រុក **ប៉ានប៉ាន** នៅខាងត្បូង ។ អ្នកស្រុកអាណាចក្រភ្នំឮដំណឹងដូច្នោះមានសេចក្តីត្រេកអរណាស់ បាននាំគ្នាទៅជួបហើយ បានលើកអោយឡើងសោយរាជ្យ ។ ស្តេចអង្គនេះបានរៀបចំក្បួនច្បាប់ទៅតាមរបៀបឥណ្ឌា ។ ក្នុងចំណោមដែលស្តេចសោយរាជ្យតៗមកមានស្តេចឈ្មោះ **ឆេ លី តោ ប៉ា ម៉ោ** (ស្រីឥន្ទ្រវរ្ម័ន ឬស្រេស្ឋវរ្ម័ន) បានបញ្ជាអោយយកសារនិងដង្វាយទៅថ្វាយព្រះចៅក្រុងចិនជាច្រើនលើកគឺនៅគ.ស.៤៣៤-៤៣៥និង៤៣៨ ។ គឺស្តេចអង្គនេះដែរ ដែលចង់រក្សាចំណងមិត្តភាពជាមួយប្រទេសចិននៅឆ្នាំ៤៣១-៤៣២បានប្រកែកមិនព្រមជួយប្រទេសចាម្ប៉ាក្នុងការដណ្តើមយកខេត្តតុងកឹងរបស់ចិន ។

ពង្សាវតាររាជវង្សស៊ីនខាងត្បូងបាននិយាយថា ប្រហែល១០ឆ្នាំ ក្រោយកាលកំណត់ ៤៣១-៤៣២ ស្តេចសោយរាជ្យនៅអាណាចក្រភ្នំគឺព្រះបាទ **ចោយេប៉ាម៉ោ** (ជ័យវរ្ម័ន)ដែលមាននាមត្រកូលថា

**គាវនេនឃូ**បានសេចក្តីថាជាស្តេចក្នុងរាជវង្ស **កៅណ្ឌិន្យ**ដែរ ។ តាមលោកP . Pelliot គឺស្តេចអង្គនេះ ហើយដែលបានបញ្ជូនពួកឈ្មួញទៅក្រុងកង់តុងដែលពេលត្រឡប់មកវិញត្រូវខ្យល់ព្រះបោកបក់ច្រាន អោយទៅជាប់នឹងឆ្នេរប្រទេសលិន យី ជាមួយនិងព្រះភិក្ខុឥណ្ឌា **នាគសេន** ដែលបានធ្វើដំណើរទៅជាមួយដែរ ។ ព្រះភិក្ខុអង្គនេះបាននិមន្តត្រឡប់មកអាណាចក្រភ្នំវិញតាមផ្លូវកាត់ ហើយនៅគ. ស. ៤៨៤ ត្រូវព្រះបាទជយវរ្ម័នបញ្ជូនអោយនាំសារនិងជង្វាយទៅថ្វាយព្រះចៅក្រុងចិន ដើម្បីសុំជំនួយទ័ពមកវាយមន្ត្រីម្នាក់( ឬបុត្រ)ដែលបានរត់ចេញពីស្រុកទៅជ្រែករាជ្យនៅប្រទេសចាម្ប៉ា ។ ប៉ុន្តែស្តេចក្រុងចិនមិនបានយល់ព្រមតាមសំណូមពរនោះទេ ហើយដើម្បីថែរក្សាចំណងមិត្តភាពទ្រង់បានថ្វាយត្រឡប់មកវិញនូវសំពត់ព្រៃដែលមានពណ៌ប្លែកៗតែប៉ុណ្ណោះ ។ ម្យ៉ាងទៀតគឺនៅក្នុងរជ្ជកាលរបស់ស្តេចអង្គនេះ ហើយដែលមានភិក្ខុពីរអង្គនៃអាណាចក្រភ្នំគឺ **សង្ឃបាល** និង **មន្ទ្រសេន** បាននិមន្តទៅគង់នៅប្រទេសចិនដើម្បី ជួយបកប្រែគម្ពីរផ្សេងៗ ។ នៅគ. ស. ៥០៣ ព្រះអង្គទ្រង់ចាត់អោយនាំ ព្រះពុទ្ធរូបធ្វើពីផ្កាថ្ម និងវត្ថុផ្សេងៗ ទៀតទៅថ្វាយព្រះចៅក្រុងចិន ។

ដោយសំអាងទៅលើសេចក្តីរាប់អានដែលស្តេចក្រុងចិនមានចំពោះព្រះបាទ**កៅណ្ឌិន្យជយវរ្ម័ន**គេ គអាចចាត់ទុកថារជ្ជកាលរបស់ព្រះអង្គជាសម័យមួយរុងរឿងបំផុតនៃប្រវត្តិអាណាចក្រភ្នំ ។

ព្រះបាទ **កៅណ្ឌិន្យជយវរ្ម័ន** សោយទីវង្គតនៅគ. ស. ៥១៤ ។ ព្រះអង្គពុំបានបន្សល់ទុកនូវសិលាចារឹកទេ ។ តែព្រះអគ្គមហេសីព្រះនាម **កុលប្រភាវតី** និងបុត្រឈ្មោះ **គុណវរ្ម័ន** បានបន្សល់ទុកនូវសិលាចារឹកមួយរៀងៗខ្លួន ។

ក្នុងសិលាចារឹកដំបងដែក(ខាងត្បូងខេត្តតាកែវ) ព្រះនាង **កុលប្រភាវតី** បាននិយាយពីការកសាងអាស្រមមួយ ។ សិលាចារឹកនេះមានលក្ខណៈជាវិស្ណុនិយម ។ ក្នុងសិលាចារឹកមួយទៀតដែលមានលក្ខណៈវិស្ណុនិយមដែរ ហើយដែលគេបានរកឃើញនៅវាលភក់ គេឃើញនិយាយពីការកសាងទេវាល័យមួយសំរាប់តំកល់ព្រះវិស្ណុបាទ ។ តាមគេប៉ាន់ស្មានមើលទៅ ព្រះមាតារបស់ **គុណវរ្ម័ន** គ្មានអ្នកណាក្រៅពីព្រះនាង **កុលប្រភាវតី**ទេ ហើយគឺ **គុណវរ្ម័ន** នេះហើយជាបុត្ររបស់ព្រះបាទ**កៅណ្ឌិន្យជ័យវរ្ម័ន** ដែលត្រូវព្រះជេដ្ឋាឈ្មោះ **លីវតោប៉ាម៉ោ** (រុទ្រវរ្ម័នបុត្ររបស់ស្នំម្នាក់) ធ្វើគត់ នៅគស. ៥១៤ ដើម្បីដណ្តើមយករាជសម្បត្តិសោយ ដូចដែលពង្សាវតាររាជវង្សលាងបានកត់ទុក ។ **រុទ្រវរ្ម័ន** ជាស្តេចចុងក្រោយបង្អស់នៃអាណាចក្រភ្នំ ។ ព្រះអង្គបានបញ្ជូនទូតទៅប្រទេសចិនជាច្រើនដងនៅចន្លោះគ. ស. ៥១៧ និង៥៣៥ ។ រាជទូតអាណាចក្រភ្នំម្នាក់ដែលបាននាំសួយជាសត្វរមាសមួយ ទៅថ្វាយស្តេចក្រុងចិននៅឆ្នាំ៥៣៩ បានទូលថា នៅប្រទេសខ្លួនមានព្រះកេស១សសៃវែង ៣ម៉ែត្រ ។ លុះទ្រង់ជ្រាបដំណឹងនេះហើយ ព្រះចៅ **លាងវូឌី** បានបញ្ជាអោយព្រះសង្ឃ **ឆេយុនប៉ាវ** និមន្តមកអាណាចក្រភ្នំជាមួយរាជទូតនោះ ដើម្បីនាំយកព្រះកេសនោះទៅប្រទេសចិន ។ សិលាចារឹកសំស្ក្រឹត នៅបាទីបាននិយាយថាព្រះអង្គនៅសោយរាជ្យនៅឡើយ នៅពេលដែលគេបានធ្វើការកសាងខាង ព្រះពុទ្ធសាសនាដែលមានចារ

ទុកក្នុងឯកសារនោះ ។ បើតាមពង្សាវតាររាជវង្សលាងពុទ្ធសាសនានៅសម័យនោះរុងរឿងណាស់ ព្រោះឯកសារនេះបាននិយាយថា មានគណៈបេសកកម្មទូតចិនមួយត្រូវបានបញ្ជូនមកអាណាចក្រភ្នំនៅចន្លោះគ.ស.៥៣៥ និង៥៤៥ ដើម្បីសូមអោយអធិរាជអាណាចក្រនេះបញ្ជូនទៅប្រទេសចិនវិញនូវអ្នកប្រាជ្ញនិងគម្ពីរខាងពុទ្ធសាសនា ។ គ្រានោះ មានឥណ្ឌាម្នាក់ឈ្មោះ **បរមាថ៌ឬ គុណរតន** បានមកស្នាក់នៅអាណាចក្រភ្នំ ព្រះចៅអធិរាជក៏បានបញ្ជូនវរជននេះអោយទៅបំពេញបេសកកម្មដោយនាំយកទៅជាមួយនូវគម្ពីរជាច្រើន ហើយដែលទៅដល់ប្រទេសចិននៅគ.ស.៥៤៦ ។

គួរកត់សំគាល់ថា ការដែលព្រះបាទ **រុទ្រវរ្ម័ន** ឡើងសោយរាជ្យដោយខុសទំនងដូច្នេះ បានបណ្តាលអោយមានការីកវររហូតដល់អាណាចក្រភ្នំត្រូវរលំរលាយជាស្ថាពរនៅពាក់កណ្តាលទី២នៃស.វ.ទី៦ ។

## គ. អរិយធម៌ខ្មែរនៅសម័យអាណាចក្រភ្នំ

ដំណើរវិវត្តន៍នៃប្រវត្តិសាស្ត្របានបង្ហាញថា អាណាចក្រភ្នំបានទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាយ៉ាងខ្លាំងអស់ពីរលើក គឺមួយលើកនៅដើមគ.ស.ទី១ និងមួយលើកទៀតនៅដើមគ.ស.ទី៥ ។ តទៅទៀត យើងនឹងសាកល្បងគូសវាសរូបភាពសង្គមខ្មែរនៅសម័យនោះ ដោយពឹងផ្អែកទៅលើឯកសារចិន(២៨)និងសិលាចារឹក ។

### ១. ជីវភាពសង្គម : លក្ខណៈមនុស្ស-ការរស់នៅ -ទំនៀមទំលាប់

ឯកសារចិនជាច្រើនបាននិយាយបញ្ជាក់ថា មនុស្សនៅអាណាចក្រភ្នំមានសម្បុរខ្មៅ សក់រួញអង្កាជី រូបច្រើនមិនសូវបាន ។ ពត៌មានប៉ុណ្ណោះអាចប្រាប់យើងពីលក្ខណៈនរវិទ្យារបស់ជនជាតិខ្មែរ-មនជាទូទៅ និងជាពិសេសរបស់ជនជាតិខ្មែរយើងនេះឯង ។ ដែលចិននិយាយថា "មានសម្បុរខ្មៅ " ក្តី "រូបច្រើនមិនសូវបាន "ក្តីគឺនិយាយដោយប្រៀបធៀបជាមួយនិងលក្ខណៈរបស់មនុស្សចិន ។ ប៉ុន្តែដោយមានកង្វះឯកសារជាភាសាខ្មែរនៅសម័យនោះទើបអ្នកសិក្សាស្រាវជ្រាវបានបញ្ចេញទស្សនៈប្លែកៗចំពោះម្ចាស់ដើមនៃអាណាចក្រភ្នំនេះ :អ្នកខ្លះយល់ថារដ្ឋនេះជារដ្ឋឥណ្ឌា ខ្លះទៀតយល់ថាជារដ្ឋមន ឬខ្មែរ មនផងឬ មលយូទៅវិញ ។ តាមការពិតជាតិទាំងប៉ុន្មានខាងលើនេះសុទ្ធតែបានរស់នៅក្នុងអាណាចក្រភ្នំជាមួយគ្នាទាំងអស់ ហើយអ្នកខ្លះជាអ្នកកាន់អំណាចគ្រប់គ្រងគេ(ខ្មែរនិងឥណ្ឌាខ្លះ) ឯអ្នកឯទៀតជាអ្នកត្រូវគេគ្រប់គ្រងប៉ុណ្ណោះ(មន-មលយូ)(ចំពោះបញ្ហានេះ សូមមើលអត្ថបទ "ហ្វូណានជារដ្ឋខ្មែរឬពុំមែនទេ? " ចុះផ្សាយក្នុងព្រឹត្តិប័ត្រវិទ្យាស្ថានខ្មែរមានលេខ ៥ ខែសីហា គ.ស.១៩៧៣) ។




ផែនទីអាណាចក្រភ្នំ ស. វ៣

ឯកសារចិនដដែលបាននិយាយទៀតថា មនុស្សនៅអាណាចក្រភ្នំច្រើនលែងខ្លួន អ្នកក្រស្លៀកសារុងអំបោះដើរជើងទទេ អ្នកមាននិងនាម៉ឺនស្លៀកសារុងចរបាច់ពាក់ស្បែកជើង ។ ផ្ទះសង់ខ្ពស់ពីដីប្រក់ស្លឹកចាក(?)ដែលដុះនៅមាត់សមុទ្រហើយមានការតុបតែង ។ ផ្ទះទាំងនោះសុទ្ធតែសង់ពីឈើដែលគេកាប់យកមកពីក្នុងព្រៃ មានរបងព័ទ្ធជុំវិញ ហើយផ្តុំគ្នាជាភូមិមានពី ៥០ទៅ៦០ ផ្ទះដែលមានស្រះមួយសំរាប់យកទឹកប្រើប្រាស់រួមគ្នា ។

មនុស្សនៅអាណាចក្រភ្នំគ្មានគំនិតរញ៉ិមរញ៉ាំ ត្រង់ណាស់មិនចេះលួចទេ(ឯកសារខ្លះថាមានចិត្តលោភលន់)មានការប៉ិនប្រសប់ហើយខិល ព្រោះចូលចិត្តចាប់យកមនុស្សនៅក្រុងជិតខាង ដែលមិនព្រមគោរពរាប់អានខ្លួនមកធ្វើជាខ្ញុំកំដរ ។ នៅពេលទំនេរគេចូលចិត្តលេងប្រជល់មាន់និងប្រជល់ជ្រូក ។

សង្គមអាណាចក្រភ្នំជាសង្គម “មេនិយម ” គឺគេទុកស្រីជាធំក្នុងគ្រួសារផងក្នុងសង្គមផង: រឿងនាងលីវយី លើកទ័ពទៅតទល់នឹងហ៊ុនទៀនជាភស្តុតាងមួយយ៉ាងជាក់ស្តែង ។ ឯកសារចិនបាននិយាយថា ពិធីបុណ្យការនិងបុណ្យសពមានលំនាំដូចនៅលីនយី ហើយបានបញ្ជាក់ថានៅស្រុកនោះគឺស្រីៗទៅដណ្តឹងប្រុសៗ បើដូច្នេះអ្នកស្រុក “ភ្នំ ”សម័យនោះច្បាស់ជានៅនិយម អោយស្រីទៅដណ្តឹងប្រុសនៅឡើយ ។ នេះជាធាតុមួយទៀតសំរាប់បញ្ជាក់ពីអត្ថិភាពនៃលទ្ធិ“មេនិយម”ទៀតដែរ ។ ចំពោះរឿងនេះពួកចិនបានកត់សំគាល់ម្យ៉ាងទៀតថា នៅក្នុងគ្រួសារពួកស្រីប្រុសគេអាចទាក់ទងគ្នាបានតាមទំនើងចិត្ត ។

ក្នុងករណីកាន់ទុក្ខ គេត្រូវតែកោរសក់និងកោរពុកមាត់ ឯពិធីរំលាយសពមាន៤យ៉ាង :

១. បោះសពចោលទៅក្នុងទឹកទន្លេ

២. បូជាដោយភ្លើង

៣. យកសពទៅកប់

៤. យកសពទៅ ដាក់ចោលក្នុងព្រៃស្មសានអោយសត្វស៊ី ។ ក្នុងករណីបូជាដោយភ្លើង គេតែងប្រមូលធាតុដែលនៅសល់យកទៅដាក់ក្នុងកោដ្ឋ១បិទជិត ហើយយកទៅបោះចោលក្នុងទឹកទន្លេ ។ បើជាព្រះមហាក្សត្រ កោដ្ឋនោះធ្វើពីមាស បើជានាម៉ឺនសព្វមុខមន្ត្រី គេប្រើកោដ្ឋជាប្រាក់ ហើយបើជារាស្ត្រសាមញ្ញប្រើកោដ្ឋដី ។ អ្នកស្រុកអាណាចក្រភ្នំចូលចិត្តប្រើវិធីអស្ចារ្យដើម្បីរកសេចក្តីពិត ។ កាលណាមានបាត់របស់អ្វីមួយ គេក៏យកបាយមួយពំនូតទៅដាក់នៅចំពោះព្រះភក្ត្រទេព្តារួចគេអង្វរសូមអោយព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត ។ ស្អែកឡើងគេយកបាយនោះ ទៅចែកអោយពួកខ្ញុំនៅក្នុងផ្ទះអោយបរិភោគ : ក្នុងមាត់របស់ ចោរនឹងមានឈាមហូរចេញយ៉ាងជាក់ស្តែង ហើយវាមិនអាចទំពារបាយផង ឯមាត់របស់ជនទៀងត្រង់បាយនោះអាចរអិលទៅក្នុងមាត់យ៉ាងស្រួល ។ ម្យ៉ាងទៀតបើកាលណាមានជនជាប់ចោទគេអោយជននោះអត់បាយ៣ថ្ងៃ រួចគេតម្រូវអោយលូកយកវត្ថុផ្សេងៗ ចេញពី

ទឹកកំពុងពុះឬកាន់ពូថៅឬច្រវាក់ដុតក្រហមដើរ៧ជំហាន ។ បើមានកំហុសមែនដៃរបស់ជននោះត្រូវរលាករលួយ ផ្ទុយទៅវិញគឺគ្មានហ្មងអ្វីទាំងអស់ ។

## ២. នយោបាយ និង រដ្ឋបាល

អាណាចក្រភ្នំ មានការរៀបចំផ្នែកនយោបាយតាមបែបឥណ្ឌា ។ អ្នកដឹកនាំរដ្ឋគឺព្រះរាជាដែលគង់នៅក្នុងប្រាសាទឈើ ដែលមានច្រើនជាន់ ហើយដែលមានរបងព័ទ្ធជុំវិញ ។ ព្រះរាជាមានឋានន្តរនាមជា "**ក្រុងខ្នំ** "ព្រោះយកតាមភ្នំដែលព្រះអង្គយាងឡើងទៅធ្វើសក្ការបូជាចំពោះព្រះ**មហេស្វរ**(ម៉. ស៊ីសូវឡ) និងមានតម្កល់លិង្គព្រះ **គិរីស**គឺឈ្មោះព្រះឥសូរដែលសណ្ឋិតនៅលើភ្នំនោះ ។ ដោយហេតុតែព្រះអង្គមានឋានៈជាតំណាងអាទិទេពដូច្នេះហើយបានជាអំណាចរបស់ព្រះអង្គមានទំហំទូលំទូលាយណាស់ ។ រាជ្យសម្បត្តិ ត្រូវបន្តពីបិតាទៅបុត្រ នេះជាហេតុនាំអោយមានវិបត្តិរាជវង្សច្រើនលើកច្រើនគ្រាណាស់ដែរ ។ ប៉ុន្តែជួនកាលរាស្ត្រអាចលើកវរជនដែលខ្លួនពេញចិត្តអោយឡើងកាន់អំណាចដែរ ដូចជាករណីរបស់ព្រះបាទ **ហ្វាន ចេម៉ាន់** និង **កៅណ្ឌិន្យទី២** ជាដើម ។

អធិរាជអាណាចក្រភ្នំនិយមធ្វើនយោបាយពង្រីកទឹកដី :ព្រះបាទ **ហ្វាន ចេម៉ាន់** បានលើកទ័ពជើងទឹកទៅវាយយកបានរដ្ឋជាច្រើនដាក់ជាចំណុះក្នុងចំណោមរដ្ឋទាំងនោះមានខ្លះជាខ្មែរ ខ្លះទៀតជាចាម ជាមនឬ ជាមលយូ ។ ក្នុងសង្គ្រាមវាតទឹកដីនោះ គេតែងតែចាប់យកឈ្លើយសង្គ្រាម មកធ្វើជាទាសាទាសី ។ ដោយអាស្រ័យហេតុនេះហើយបានជាយើងនិយាយថាអាណាចក្រភ្នំជាអធិរាជាណាចក្រ ហើយព្រះរាជាមានឋានៈជាមហារាជឬជាសារិកៅ (ស្តេចចក្រវាឡ) ។ រដ្ឋដែលស្ថិតក្រោមអំណាចគ្រប់គ្រងរបស់អាណាចក្រភ្នំសុទ្ធតែមានស្តេចសោយរាជ្យ ប៉ុន្តែស្តេចទាំងនោះជា "**សាមន្តរាជ** "របស់អធិរាជអាណាចក្រភ្នំ ហើយត្រូវនាំសួយសាអាករមកថ្វាយព្រះអង្គរៀងរាល់ឆ្នាំ ។ រដ្ឋខ្លះទៀតមានស្តេចសោយរាជ្យដែរ តែស្តេចទាំងនោះជារាជបុត្រឬជាព្រះញាតិអស់អធិរាជភ្នំ ។ ព្រះបាទកៅណ្ឌិន្យទី១បានប្រទានរដ្ឋបែបនេះថ្វាយទៅព្រះរាជបុត្រ ប៉ុន្តែព្រះបាទហ៊ុន ប៉ានហួងបានរំលាយរដ្ឋបែបនេះចោលវិញ ។ រដ្ឋបែបទី ២នេះហៅថា **វិស័យរដ្ឋ** ជាសម្បត្តិផ្ទាល់របស់អធិរាជភ្នំ ។ គួរកត់សំគាល់ថា រចនាសម្ព័ន្ធនយោបាយដូចបានពោលរួចមកហើយនេះឃើញថា នាំអោយមានគ្រោះថ្នាក់ច្រើនដែរ ព្រោះតែកាលណាអំណាចកណ្តាលធ្លាក់ខ្សោយ ពួកសាមន្តរាជតែងបះបោរឡើងទាមទាយកឯករាជ្យរៀងៗខ្លួន ដូចជាករណីរបស់រដ្ឋចេនឡានៅ ស.វ.ទី៦ ។

ក្នុងវិស័យនយោបាយក្រៅប្រទេស អាណាចក្រភ្នំនិយមចងស្ពានមេត្រីជាមួយប្រទេសធំៗដូចជាប្រទេសឥណ្ឌា និងជាពិសេសប្រទេសចិន ។ នយោបាយទូតខ្មែរមានសកម្មភាពយ៉ាងមមាញឹក ចាប់តាំង

ពីរជ្ជកាលរបស់ព្រះបាទ ហ្វានឆាន ។ ទំនាក់ទំនងនេះមានក្នុងវិស័យនយោបាយផង ពាណិជ្ជកម្មផងនិងវប្បធម៌ផង ។

នៅប្របព្រះអធិរាជគេឃើញមានមន្ត្រីបំរើរាជការពីរបែប គឺមន្ត្រីឆ្វេងនិងមន្ត្រីស្តាំ ។ មន្ត្រីឆ្វេងគឺមន្ត្រីអង្គុយគាល់នៅខាងឆ្វេងរីឯមន្ត្រីស្តាំគឺមន្ត្រីដែលមានសក្តិធំជាង ហើយអង្គុយនៅខាងស្តាំ ។ ក្រៅពីនេះនៅមានមន្ត្រីផ្សេងទៀតដែលមានខ្លះទៅឈរត្រួតត្រានៅតាមខេត្ត ។ ព្រះអធិរាជតែងប្រទានសវនាការជាញឹកញាប់ដល់ប្រជារាស្ត្រនិងពួកជនបរទេសដែលបានយកជង្វាយផ្សេងៗមកថ្វាយព្រះអង្គមិនដែលខាន ។ ក្នុងករណីនេះព្រះអធិរាជទ្រង់គង់ប្រថាប់ដោយទំលាក់ព្រះបាទឆ្វេងដល់ដីហើយបញ្ឈរព្រះបាទស្តាំ រួចគេក្រាលកំរាលមួយផ្ទាំងនៅចំពោះព្រះភក្ត្រព្រះអង្គ ដើម្បីយកភាជន៍មាសនិងភាជន៍ដុតគ្រឿងក្រអូបមកតំកល់លើកំរាលនោះ ។ កាលណាយាងចេញទៅក្រៅឬយាងចូលមកវិញព្រះអង្គតែងប្រថាប់លើដំរី ។ ឯពួកស្រីស្នំនិងពួកមន្ត្រីជាបរិវារក៏ជិះដំរីដែរ ។ ព្រះអធិរាជទ្រង់សព្វព្រះហឫទ័យនឹងការបរបាញ់ណាស់ហើយយាងទៅម្តងៗអស់ពេលរាប់ខែ ។

នៅអាណាចក្រភ្នំ រាស្ត្របង់ពន្ធដាជូនរាជការជាមាស ប្រាក់ ត្បូង គុជ ឬគ្រឿងក្រអូបផ្សេងៗ ។ គេមិននិយមធ្វើគុកដាក់ជនទុច្ចរិតទេ ។ បើកាលណាមានកំហុសស្រាលគេពិន័យជនមានទោស តែបើមានកំហុសធ្ងន់វិញគេយកមនុស្សទោសអោយក្រពើឬសត្វសាហាវស៊ីតែម្តង ។ក្នុងបីថ្ងៃបើសត្វអស់នោះមិនព្រមស៊ីទេគេចាត់ទុកថា គ្មានកំហុសហើយលែងអោយរួចខ្លួន ។

### *សកម្មភាពសេដ្ឋកិច្ច*

អាណាចក្រភ្នំ ដែលមានឈ្មោះថាថ្កុំថ្កើនរុងរឿង ក៏ដោយសារតែយល់នូវសារសំខាន់នៃសេដ្ឋកិច្ច ។ឯសកម្មភាពសេដ្ឋកិច្ចចម្បងនៅសម័យនោះគឺ កសិកម្មនិងពាណិជ្ជកម្មនេះឯង ។

កសិកម្មមានការចំរើនលូតលាស់ខ្លាំង ។ នេះក៏ដោយសារតែមានជោគជ័យក្នុងនយោបាយទឹក ។ យ៉ាងណាមិញ អ្នកស្រុកចេះជីកព្រែកខ្វាត់ខ្វែងដែលមានសល់ដានរហូតដល់សព្វថ្ងៃ នៅត្រង់កម្ពុជាក្រោមភាគខាងលិច ។ តាមយោបល់អ្នកជំនាញការ បណ្តាញព្រែកជីកនេះគេបានកសាងឡើង សំរាប់បង្ហូរទឹកជំនន់ទន្លេមេគង្គចោលចេញផងសំរាប់លាងអោយស្អាតនូវទឹកភក់ល្បប់ និងបន្សាបអំបិលដែលជ្រត់ជាបទៅក្នុងដីផង សំរាប់ជាគមនាគមន៍រវាងទីក្រុងទាំងឡាយ និងសំរាប់អោយសំពៅនិងទូកឆ្លងកាត់ទៅបានពីសមុទ្រចិនទៅឈូងសមុទ្រសៀម ដោយមិនបាច់កុងព័ទ្ធតាមចុងជ្រោយទឹកខ្មៅផង ។

ក្រៅពីរបរស្រែដែលចិនថា "គេព្រោះមួយឆ្នាំរួចគេច្រូតបានបីរដូវ" របរខាងចំការទំនងជាមានការលូតលាស់ណាស់ដែរ គេដាំក្រូច ទទឹម អំពៅ ស្លា ។ ល ។

ពាណិជ្ជកម្មក៏ជាវិស័យមួយមានការចំរើនលូតលាស់ណាស់ដែរ ។ ភស្តុតាងគឺគេបានរកឃើញស្នាមកំពង់ផែសមុទ្រមួយយ៉ាងធំ ។ តាមយោបល់អ្នកជំនាញការ គេថាកំពង់ផែនេះ(កំពង់ផែអូកែវ) ជាកំពង់ផែអន្តរជាតិ ព្រោះកំណាយនៅតំបន់នោះបានរកឃើញវត្ថុផ្សេង ៗដែលមកពីប្រទេសឆ្ងាយៗដូចជា ចក្រភពរ៉ូម៉ាំង ពីភពអ៊ីរ៉ង់ ប្រទេសឥណ្ឌា ។ ដូច្នេះឃើញថា នៅសម័យនោះអ្នកស្រុកអាណាចក្រភ្នំមិនគ្រាន់តែធ្វើជំនួញជាមួយប្រទេសជិតខាងតែប៉ុណ្ណោះទេ គឺបានទាក់ទងខាងផ្លូវជំនួញនេះជាមួយនឹងចិន ឥណ្ឌា រ៉ូម៉ាំង និងពែរ្សទៀតផង ។ ហើយការដែលអ្នកជំនួញមានលទ្ធភាពអាចធ្វើដំណើរទៅឆ្ងាយដូច្នេះបានក៏ព្រោះតែគេមានបច្ចេកទេសយ៉ាងខ្ពង់ខ្ពស់ក្នុងការស្ថាបនាសំពៅធំៗសំរាប់ឆ្លងកាត់សមុទ្របាន ។ ឯកសារចិនថាមានសំពៅប្រវែងប្រហែល ៣០ម៉ែត្រ ក្បាលនិងកន្សៃមានរាងជាក្បាលនិងកន្ទុយសត្វត្រី ។ ទំនិញដែលគេលក់ដូរច្រើនតែជា មាស ប្រាក់ សំពត់ព្រែ គ្រឿងកែវ ។ល ។

ឯកសារចិនបាននិយាយថា អាណាចក្រភ្នំជាកន្លែងកើតមាស ប្រាក់ ទង់ដែង សំណបាហាំង គ្រឿងក្រអូប ភ្លុកដំរី និងពេជ្រ ។ ឯកសារនេះបានបញ្ជាក់ទៀតថា ពេជ្រនេះគេមុជទៅរកនៅបាតសមុទ្រ ហើយមានភាពរឹងណាស់យកដែកដំមិនខូចទេ តែខូចដែកវិញ ។ ម្យ៉ាងទៀត អ្នកស្រុកប៉ិនប្រសប់ណាស់ក្នុងរបរធ្វើជាងមាសឬប្រាក់ ដូចជាធ្វើចិញ្ចៀនឬកងដៃមាស ធ្វើគ្រឿងចានក្បានប្រាក់ ។ អ្នកស្រុកប៉ិនណាស់ដែរក្នុងរបរសូនរូប ត្បាញសូត្រ ចរបាច់ ស្លកែវ ។ ល ។

## ៣. វប្បធម៌

ឯកសារចិននិយាយថានៅអាណាចក្រភ្នំមានសៀវភៅនិងកន្លែងទុកបណ្ណសារ តែគួរអោយស្តាយព្រោះសៀវភៅទាំងនោះប្រហែលជាត្រូវវិនាសអស់ទៅហើយ ដែលជាហេតុនាំអោយយើងមានការលំបាកច្រើនក្នុងការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្នុងសម័យនេះ ។ សព្វថ្ងៃនេះយើងមិនដឹងថាអក្សរ និងភាសាដែលដូនតាយើងប្រើក្នុងសៀវភៅទាំងនោះ មានបែបផែនយ៉ាងណាទេ ។ បើយើងសំអាងលើសិលាចារឹកទាំង៤ផ្ទាំង ដែលគេបានរកឃើញរហូតសព្វថ្ងៃឃើញថា ភាសាផ្លូវការក្នុងសម័យនោះគឺភាសាសំស្ក្រឹត ។ ត្រង់នេះមិនមែនមានន័យថានៅសម័យនោះគេមិនប្រើភាសាខ្មែរសោះទេ : ឈ្មោះស្រុកក្តី (វ្នំ) ឈ្មោះរាជធានីក្តី(ទមាក់ ឬទល្មាក់)ជាភស្តុតាងមួយបញ្ជាក់ថាភាសាខ្មែរក៏គេប្រើទន្ទឹមនឹងភាសាសំស្ក្រឹតដែរ ។ យើងសង្ឃឹមថា ក្នុងអនាគតអ្នកស្រាវជ្រាវនឹងរកឃើញសិលាចារឹកជាភាសាខ្មែរបូរាណក្នុងចំណោមសិលាចារឹកប្រើភាសាខ្មែរបូរាណដែលគ្មានចុះកាលកំណត់ ប៉ុន្តែដែលទំរង់អក្សរអាចអោយភ្ជាប់មកសម័យអាណាចក្រភ្នំបាន ។

ក្នុងវិស័យជំនឿសាសនា មនុស្សនៅអាណាចក្រភ្នំបានកាន់សាសនាធំៗទាំងពីររបស់ឥណ្ឌា គឺព្រាហ្មណ៍សាសនានិងពុទ្ធសាសនា តែគេមិនដឹងច្បាស់ថាសាសនាណាមួយបានចូលមកស្រុកយើងមុនគេទេ ។ បើតាមឯកសារខ្លះ ព្រះបាទ **អសោក** បានបញ្ជូនសមណទូត២អង្គមកកាន់សុវណ្ណភូមិ ដើម្បីផ្សាយព្រះពុទ្ធសាសនានៅស. វ. ទី ៣មុនគ. ស. (29) ។ គេមិនដឹងច្បាស់ថាសុវណ្ណភូមិនេះត្រូវនឹងតំបន់ណា ស្រុកណាអោយបានប្រាកដទេ ។ អ្នកសិក្សាស្រាវជ្រាវគ្រាន់តែបានស្របគ្នាថា សុវណ្ណភូមិនេះត្រូវនឹងភូមិភាគអាស៊ីអគ្នេយ៍នេះឯង ។ ម្យ៉ាងទៀតបុរាណវត្ថុផ្សេងៗដែលទាក់ទងនឹងព្រះពុទ្ធសាសនាហើយដែលគេរកឃើញនៅតំបន់ផ្សេងៗ នៅអាស៊ីអគ្នេយ៍នេះមានអាយុនៅ ស. វ. ទី ៣-៤ នៃគ. ស. ប៉ុណ្ណោះ ។ ដោយហេតុនេះហើយទើបមានបញ្ហាចោទឡើងថា បើត្រូវផ្សាយចាប់ពីស. វ. ទី ៣មុនគ. ស. ហេតុអ្វីបានជាព្រះពុទ្ធសាសនាអោយផ្លែផ្កាតែនៅសតវត្សទី ៣-៤ នៃគ. ស. ទៅវិញ គឺអស់រយៈពេលដល់ទៅ៦ ឬ៧ ស. វ. ?

តែទោះបីយ៉ាងនេះក៏ដោយ ក៏គេអាចដឹងថាព្រះពុទ្ធសាសនាដែលនាំចូលស្រុកយើងដំបូងគឺ ព្រះពុទ្ធសាសនាហីនយាន ប្រើភាសាសំស្ក្រឹត ដែលឥណ្ឌានៅ **អមរាវតី**រាប់អាននៅស. វ. ទី២-៣នៃគ. ស. ។ សិលាចារឹកវ៉ូកាញ់ និងសិលាចារឹកតាព្រហ្មបាទីអាចបញ្ជាក់ពីលក្ខណៈនេះបាន ។ ព្រះពុទ្ធសាសនាមានភាពរុងរឿងជាពិសេសនៅស. វ. ទី៥-៦ ក្នុងរជ្ជកាលព្រះបាទកៅណ្ឌិន្យជយវរ្ម័ននិងរុទ្រវរ្ម័ន ដោយមានការបញ្ជូនព្រះសង្ឃជាតិខ្មែរនិងជាតិឥណ្ឌាទៅកាន់ប្រទេសចិន ដើម្បីយកឯកសារផ្សេងៗនិងព្រះពុទ្ធរូបទៅថ្វាយស្តេចក្រុងចិនឬជួយប្រែគម្ពីរពីសំស្ក្រឹតទៅជាចិនទៀតផង ។ ព្រះសង្ឃ **សង្ឃបាល** បានគង់នៅប្រទេសចិនរហូតដល់១៦ឆ្នាំ ហើយបានធ្វើការនៅ៥ការិយាល័យ ។ ព្រះចៅក្រុងចិនមានការស្ញើចយ៉ាងខ្លាំងចំពោះព្រះអង្គ ហើយចាត់ទុកថាជាព្រះគ្រូទៀតផង ។

នៅពេលដែលទ័ពចេនឡាចូលវាយយកអាណាចក្រភ្នំ ពុទ្ធសាសនាហីនយាន ភាសាសំស្ក្រឹតប្រហែលជានៅរុងរឿងនៅឡើយ ។ លុះដល់ចុងស. វ. ទី៧ ទើបឮព្រះសង្ឃចិននាម យី ស៊ីង ដែលបាននិមន្តត្រឡប់ពីប្រទេសឥណ្ឌាទៅកាន់ចិនវិញមានថេរដីការថា "ពីដើមព្រះធម៌មានភាពរុងរឿងហើយផ្សព្វផ្សាយទៅគ្រប់ទិសទី តែឥឡូវនេះស្តេចកំណាចមួយអង្គបានបំផ្លិចបំផ្លាញចោលអស់ហើយ ព្រះសង្ឃរកតែមួយអង្គមិនបានផង " ។ ដូច្នេះ ព្រះពុទ្ធសាសនាហីនយានប្រហែលជារលាយបាត់បង់ចាប់ពីពេលនោះទៅរហូតដល់ស. វ. ក្រោយទើបឃើញមានពុទ្ធសាសនាបែបមហាយានចូលមកផ្សព្វផ្សាយលទ្ធិរបស់ខ្លួន ។

ចំណែកខាងសាសនាព្រាហ្មណ៍ គេឃើញមានការគោរពចំពោះព្រះឥសូរព្រះវិស្ណុ ព្រះហរិហរ (វិស្ណុ និងឥសូររួមគ្នា)និងព្រះព្រហ្ម ។ នៅខាងដើមសម័យអាណាចក្រភ្នំ គណៈឥសូរនិយមទំនងជាមានឋានៈជាសាសនាផ្លូវការផងព្រោះឯកសារចិនថា ព្រះរាជាតែងតែយាងឡើងលើភ្នំ មុំតាន់ ដើម្បីទៅធ្វើ

សក្ការបូជាចំពោះព្រះមហេស្វរៈ ។ ប៉ុន្តែក្រោយមកមានអធិរាជខ្លះ បានផ្លាសសាសនាពីឥស្សរនិយមមកកាន់ពុទ្ធសាសនាវិញ ដូចជាព្រះបាទ កៅណ្ឌិន្យជយវរ្ម័នជាដើម ។ ខាងគណៈវិស្ណុនិយមឃើញមានបដិមាព្រះវិស្ណុ និងអវតារបស់ព្រះអង្គជាច្រើននៅតំបន់ភ្នំដា ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ក្រៅពីនេះសិលាចារឹករបស់ព្រះនាង **កុលប្រភាវតី** និងព្រះ **គុណវរ្ម័ន** ក៏មានលក្ខណៈវិស្ណុនិយមដែរ ។

ក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទបូរាណទាំងឡាយសុទ្ធសឹងតែកសាងពីដីឥដ្ឋ ។ ដូច្នេះហើយបានជាពុំមានប្រាសាទណាមួយក្នុងចំណោមប្រាសាទទាំងនោះអាចនៅស្ថិតស្ថេររហូតដល់សព្វថ្ងៃនេះ ក្រៅពីប្រាសាទដែលគេសាងដោយលុងភ្នំ ។ យឿនសំនង់ផ្សេងៗដែលគេបានរកឃើញនៅកំពង់ផែអូកែវនិងនៅអង្គរបូរីក៏ជាសំនង់ពីឥដ្ឋ ។ ខាងសិល្បៈបដិមា គេបានរកឃើញពុទ្ធរូប និងទេវរូបជាច្រើននៅតំបន់ភ្នំដាស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចជាពុទ្ធរូបវត្តរំលក រូបព្រះវិស្ណុ ព្រះពលរាម ព្រះកល្កិន ព្រះគ្រឹស្ណគោវធ៌ន ។ ស្នាដៃទាំងអស់នេះនៅមានលក្ខណៈជាឥណ្ឌានៅឡើយត្រង់ដែលមានរាងធាត់កាច់ចង្កេះ និងមានធ្នូឬចន្ទល់ទ្រឬ ធ្លាក់ជាប់នឹងជញ្ជាំងថ្ម គឺថាពុំទាន់មានលក្ខណៈជាចម្លាក់សោតពេញលេញនៅឡើយទេ ។

រួមសេចក្ដីមកឃើញថាខ្មែរនៅអាណាចក្រភ្នំបានកសាង អរិយធម៌មួយដ៏ត្រចះត្រចង់មានលក្ខណៈខ្ពង់ខ្ពស់ជាងអរិយធម៌ជនជាតិជិតខាងក្នុងសម័យជាមួយគ្នានោះ ។ ទោះបីអរិយធម៌នេះនៅពុំទាន់មានលក្ខណៈជាតិពិតប្រាកដនៅឡើយ តែវាជាកេរមត៌កមួយយ៉ាងសំខាន់សំរាប់កូនចៅជំនាន់ក្រោយៗដែលមានគំនិតចេះយកធាតុបរទេសនេះ ទៅកែឆ្នៃដោយផ្សំនឹងធាតុជាតិដើម្បីបង្កើតជាអរិយធម៌មួយដែលមានលក្ខណៈរឹងប៉ឹង ហើយឡើងដល់កំរិតកំពូលនៅសម័យអង្គរនេះឯង ។

# ជំពូក ៧

# អាណាចក្រចេនឡា

## ក. បញ្ហាឈ្មោះចេនឡា

កាលដើមឡើយ ចេនឡាជាសាមន្តរដ្ឋរបស់អាណាចក្រភ្នំ ។ ក្រោយមកបានវាយយកអាណាចក្រនេះបញ្ចូលជាចេនឡាធំ ហើយបានទទួលឋានៈជារដ្ឋអធិបតេយ្យរហូតដល់ពាក់កណ្តាលទី២ នៃស.វ. ទី៨ ។

ឈ្មោះចេនឡាជាពាក្យដែលអ្នកប្រវត្តិសាស្ត្រហៅតាមចិន ហើយរហូតមកដល់សព្វថ្ងៃនេះគេមិនទាន់ដោះស្រាយបញ្ហានេះអោយជ្រះស្រឡះនៅឡើយទេ ។ ចំពោះបញ្ហាឈ្មោះចេនឡានេះអ្នកសិក្សាស្រាវជ្រាវបានខិតខំដោះស្រាយណាស់ដែរ ដោយបញ្ចេញជាទស្សនៈឬសម្មតិកម្មផ្សេងៗដូចមានតទៅនេះ ÷

### ១. សម្មតិកម្មលោក Paul Pelliot (30)

អ្នកប្រាជ្ញរូបនេះយល់ថា ពាក្យចេនឡាទំនងជាបានកើតឡើងដោយការផ្សំពាក្យ "ចិន" និង "រាប "

**ចិន + រាប > ចិនឡា**

អ្នកដែលគាំទ្រសម្មតិកម្មនេះបានពន្យល់ថា ពួកខ្មែរចេនឡាដែលមានព្រំប្រទល់នៅជាប់នឹងអាណាខេត្តចិននៅតំបន់ឥណ្ឌូចិនខាងជើង ប្រហែលជាធ្លាប់មានជម្លោះនឹងចិន ហើយធ្លាប់បានទទួលជោគជ័យលើជនជាតិនេះផង ក៏បានដាក់ឈ្មោះកន្លែងនោះថា ចិនរាបទៅ ហើយដែលចិនថាត្រាប់តាមខ្មែរមិនច្បាស់ក្លាយជាចេនឡាវិញ ។

## ២. ទស្សនៈ លោកកេង វ៉ាន់សាក់

លោកសាស្ត្រាចារ្យ **កេង វ៉ាន់សាក់** មានគំនិតប្រហាក់ប្រហែលនិងគំនិតខាងលើនេះដែរ តែលោកយល់ថាពាក្យចេនឡាក្លាយមកពីពាក្យ " ចិន " និង " លា " ទៅវិញ៖

**ចិន** + **លា** > **ចិនឡា**

ក្នុងសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សារាជាណាចក្រ (ឥឡូវព្រឹទ្ធសភា) ស្តីពីការបង្កើតវិទ្យាស្ថានខ្មែរ-មនកាលពីថ្ងៃទី១៦ខែកុម្ភៈ ១៩៧០ លោកកេងវ៉ាន់សាក់ បានថ្លែងបំភ្លឺអង្គប្រជុំថា ដោយហេតុតែជនជាតិចិនមិនអាចទៅត្រួតត្រាកន្លែងនោះបាន ក៏ដកថយទៅវិញឬ "លា"ទៅវិញ ទើបមានឈ្មោះថា "ចិនលា"ៗដូច្នេះ ។

## ៣. ទស្សនៈតាមលោក លី ធាមតេង

ក្នុងសៀវភៅ " កំណត់ហេតុរបស់ជីវតាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា "បោះពុម្ពផ្សាយនៅភ្នំពេញឆ្នាំ ១៩៧២ ត្រង់ទំព័រទី៧៤-៧៥ លោកលី ធាមតេងបានសរសេរថា : "កាលខ្ញុំទៅស្រុកចិនជួបនឹងអ្នកស្រាវជ្រាវចិនម្នាក់ឈ្មោះ ស៊ីវម៉េង គាត់ប្រាប់ខ្ញុំថា "គាត់ឃើញឯកសារមួយនិយាយពីឈ្មោះចេនឡានេះ ។គឺដើមឡើយចិនហៅប្រទេសមួយដែលស្ថិតនៅខាងលើប្រទេសហ្វូណន ។ប្រទេសនោះមានព្រៃក្រាស់ណាស់ ហើយសម្បូណ៌ឃ្មុំយកក្រមួនធ្វើទៀន ។ ពួកចិនតែងធ្វើដំណើរតាមសំពៅមកទិញដូរយកក្រមួនសុទ្ធ គឺក្រមួនយកពីឃ្មុំ ដើម្បីយកទៅលក់នៅឯស្រុកគេសំរាប់ធ្វើទៀនហើយគេនាំគ្នាសន្មតហៅស្រុកនោះថាក្រមួនសុទ្ធៗ គឺថា **ចេន**ឬ **ចេង** ប្រែថាសុទ្ធ ឯ **ឡា** ឬ **ឡាក់**ប្រែថាក្រមួន ឬ ឃ្មុំ ឬ ទៀន (ភាសាចិន គេដាក់គុណនាមមុននាម) បូករួមមកបានន័យថា " ស្រុកក្រមួនសុទ្ធ " ។

## ៤. ទស្សនៈរបស់លោកឆត្រាប្រេមឬឌី

ក្នុងជំពូកទី២ ស្តីអំពីអំបូរខ្មែរ-មនយើងបានជំរាបពីទស្សនៈនេះម្តងរួចមកហើយ ។ ឥឡូវនេះយើងសូមរំឭកឡើងវិញម្តងទៀត ។ ក្នុងអត្ថបទមួយមានចំនងជើងថា "ខ្មែរមកពីណា ? "ផ្សាយតាមវិទ្យុជាតិកាលពីខែកុម្ភៈ១៩៧៣ លោកឆត្រាប្រេមឬឌីបានបញ្ចេញយោបល់របស់លោកថា កាលពីសម័យបុរាណប្រទេសខ្មែរផ្នែកខាងលើហៅថា "**ជាន់លើ** "ឯផ្នែកខាងក្រោមហៅថា "ក្រោមពូជ " ។ ពាក្យ **ជាន់លើ** ចិនហៅមិនច្បាស់ក៏ក្លាយជា **ចេនឡា**

**ជាន់លើ** > **ចិនឡា**

### ៥. ទស្សនៈលោក ពៅ ឈិន

ក្នុងជំពូកទី ២យើងបានឃើញទស្សនៈរបស់លោកពៅឈិនម្តងរួចមកហើយ ចំពោះពាក្យថា "ខ្មែរ-ខម-កម្ពុជា " ។ ឥឡូវនេះយើងលើកយកទស្សនៈរបស់លោកចំពោះពាក្យ " **ចេនឡា** " មកពិនិត្យទៀត ។ ក្នុងសៀវភៅ "**អរិយធម៌ខ្មែរ-មន** " ដដែលត្រង់ទំព័រ ៣២-៣៣ លោកបានសរសេរថា "... ហើយពុំទាន់មានស្តេចទេ គឺមានតែជាកុលសម្ព័ន្ធធំៗពីរគឺ មន១ និងខម១ប៉ុណ្ណោះឯង ។ ថាកុលសម្ព័ន្ធមននៅតាមមាត់ទន្លេមេណាមក្នុងស្រុកសៀមរហូតទៅដល់ខាងត្បូងប្រទេសភូមា ឯកុលសម្ព័ន្ធខមនៅចាប់តាំងពីស្រុកបាភ្នំ- លពបូរី- ស្រីអាយុធ្យា និងនៅលើដីកោះគោកធ្លកតាមជួរភ្នំដងរែករហូតទៅដល់ស្រុកចិនទើបបានជាមានពាក្យថា **ចិនឡា** ។ មួយទៀតថា ដោយហេតុតែដីកោះទាំងនោះមានមាសច្រើន ទើបបានជាមានពាក្យថា សុវណ្ណភូមិនោះឯង " ។

### ៦. ទស្សនៈលោក M Ghosh

ក្នុងសៀវភៅរបស់លោក M . Ghosh ដែលមានចំនងជើងថា A history of Cambodia លោកបានស្នើពាក្យ ចន្ទ្របូរា (Chamtrapura) សំរាប់ដោះស្រាយចំណោទពាក្យចេនឡា ព្រោះលោកយល់ថា "ចន្ទ្រា " គឺពិតជានាមសព្ទផ្សេងមួយទៀតរបស់ក្រុងវៀងចន្ទ (Vientiane) ។

ទស្សនៈនេះត្រូវបានលោក តាន់ គីមហួន អតីតសកលវិទ្យាធិការនៃសកលវិទ្យាល័យក្សេត្រសាស្ត្រគាំទ្រទាំងស្រុង ។ ក្នុងអត្ថបទប្រែជាភាសាខ្មែរមួយមានចំនងជើងថា " គំនិតត្រិះរិះចំពោះប្រវត្តិសាស្ត្រខ្មែរ " ចុះផ្សាយក្នុងទស្សនាវដ្តីហ្វូណនលេខ៣ខែកុម្ភៈ១៩៧០ លោកបានសរសេរថា : "... ប៉ុន្តែនាមសព្ទចន្ទ្របូរាពិតជាសមរម្យជាង ព្រោះនាកាលសម័យនោះមានក្សត្ររដ្ឋ (Principautés) ច្រើនណាស់នៅប៉ែកខាងជើង មាននាមសព្ទ ជាភាសាសំស្ក្រឹតដែលខាងចុងមានសព្ទនាមថា "បូរា "(Pura) ដូចយ៉ាងឥស្សនាបូរា( Içanapura = សម្បូណ៍ព្រៃគប់ = Sambor Prey Kup) ភិម៉ាបូរា (Bhimapura = ភិម៉ៃ = Phimai ) ។ ទំរាំដល់ពេលណាមានតឹកតាំងផ្តុំយមតិវិញនោះគេអាចហៅថា "ចន្ទ្រាបូរា" (Chandra-pura) នូវរដ្ឋខ្មែរទី២គឺចេនឡានេះឯង " ។

## ខ. ចំណុចចេនឡា អាណាចក្រភ្នំ

គួរគប្បីរំឭកឡើងវិញថា ព្រះបាទរុទ្រវរ្ម័នបានបញ្ជូនទូតទៅប្រទេសចិនលើកចុងក្រោយបង្អស់នៅឆ្នាំ ៥៣៩ ។ ឯកសារចិនបានអោយដឹងថា អាណាចក្រភ្នំនៅបញ្ជូនទូតទៅប្រទេសចិននៅពាក់

កណ្តាលទី១នៃស.វ.ទី៧នៅឡើយ តែបានបញ្ជាក់ថារាជធានី តូម៉ូ ត្រូវបំផ្លិចបំផ្លាញហើយត្រូវលើកទៅតាំងនៅទិសខាងត្បូង ។ ឯកសារចិនដដែលបានអោយពត៌មានថា អាណាចក្រចេនឡាស្ថិតនៅនិរតីប្រទេសលិនយីហើយពីដើមជាសាមន្តរដ្ឋមួយរបស់អាណាចក្រភ្នំ ។ មជ្ឈមណ្ឌលរបស់ចេនឡាស្ថិតនៅត្រង់វាលទំនាបភាគកណ្តាលនៃទន្លេមេគង្គ ក្នុងតំបន់ **បាសាក់** ក្នុងប្រទេសឡាវសព្វថ្ងៃ ។

ឯកសារចិននិយាយថា "នៅជិតរាជធានីមានភ្នំមួយឈ្មោះ **លិងកៀវប៉ូផូ** ។ នៅលើកំពូលភ្នំនោះមានប្រាសាទមួយមានទាហាន១០០០នាក់ចាំយាមជានិច្ច ហើយឧទ្ទិសថ្វាយចំពោះព្រះ **ផូតូលី** ដែលគេត្រូវយកមនុស្សមកធ្វើបូជា ។ រៀងរាល់ឆ្នាំ ព្រះរាជាត្រូវយាងទៅក្នុងប្រាសាទនោះដើម្បីប្រារព្ធធ្វើដោយព្រះអង្គនូវបូជាយញ្ញក្នុងពេលយប់ " ។

ព្រះ**ផូតូលី** តាមឯកសារចិននេះគេយល់ថា ជាព្រះនាមព្រះឥសូរ ដែលគេនិយមគោរពបូជានៅប្រាសាទ **វត្តភូ** គឺព្រះ **ភទ្រេស្វរ** ឯភ្នំឈ្មោះ **លិងកៀវប៉ូផូ** គឺត្រូវនឹងភ្នំ **លិង្គបវ៌ត** ស្ថិតនៅតំបន់វត្តភូហ្នឹងដែរ ។

បើតាមសិលាចារឹកបក្សីចាំក្រុង(ស.វ.ទី១០) ស្តេចចេនឡាមានដើមកំណើតមកពីឥសី **កម្ពុ - ស្វយម្ភុវ** និងនាងទេពអប្សរ **មេរា** ដែលព្រះឥសូរបានប្រទានអោយជាមហេសី ។ ស្តេចដំបូងមាននាមថា **ស្រុតវរ្ម័ន** ឯព្រះរាជបុត្រមានព្រះនាមថា **ស្រេស្ឋវរ្ម័ន** ហើយទ្រង់បានកសាងក្រុង **ស្រេស្ឋ-បុរ** ដែលទំនងជាស្ថិតនៅតំបន់បាសាក់ ។ សិលាចារឹកបក្សីចាំក្រុងដដែលបានផ្តល់ពត៌មានបន្ថែមទៀតថាស្តេចទាំងនេះទំនងជាបាន " រំដោះអ្នកស្រុកអោយផុតចាកពីច្រវាក់សួយសារអាករ " គឺថា បានរំរើបំរាស់ខ្លួនអោយចេញពីអំណាចគ្រប់គ្រងរបស់អាណាចក្រភ្នំ ។ នៅពាក់កណ្តាលទី ២នៃស.វ.ទី ៦ចេនឡាមាន អានុភាពកាន់តែខ្លាំងឡើងៗ ហើយចាប់ផ្តើមវាយលុកប្រឆាំងនឹងអាណាចក្រភ្នំ ។ កាលណោះព្រះរាជាចេនឡាមានព្រះនាមថា **ភវវរ្ម័ន** ជាបុត្ររបស់ **វីរវរ្ម័ន** និងជាចៅរបស់ព្រះបាទ **រុទ្រវរ្ម័ន** ។ ព្រះអង្គបានរៀបរាជាភិសេកជាមួយក្សត្រី **កម្ពុជរាជលក្ស្មី** ដែលជាព្រះញាតិខាងមាតាព្រះបាទស្រេស្ឋវរ្ម័ន ។ ដោយហេតុនេះហើយបានជាស្លោកទី១១ នៃសិលាចារឹកបក្សីចាំក្រុងបានបញ្ជាក់ថា កូនចៅឥសី **កម្ពុ** បានភ្ជាប់ **សូរ្យវង្ស** (ខាងចេនឡា )ទៅនឹង **សោមវង្ស** (ខាងអាណាចក្រភ្នំ) ។

ចំពោះបុព្វហេតុនៃចំបាំងរវាងចេនឡានិងអាណាចក្រភ្នំនេះមានសម្មតិកម្ម ២សំខាន់ដូចតទៅ ៖

- អ្នកខ្លះយល់ថាព្រះបាទ **ភវវរ្ម័ន** ដែលជាចៅរបស់ព្រះបាទ រុទ្រវរ្ម័ន ហើយបានលើកទ័ពមកវាយអាណាចក្រភ្នំវិញនេះ គឺដើម្បីប្រឆាំងនឹងការប៉ុនប៉ងរបស់បក្សពួកគុណវរ្ម័ន ក្នុងការដណ្តើមយករាជបល្ល័ង្កទៅវិញ ។ បន្ថែមលើនេះគេយល់ថា ប្រហែលជាមានទំនាស់ក្នុងសាសនាទៀត ព្រោះព្រះបាទរុទ្រវរ្ម័នជាអ្នកកាន់ពុទ្ធសាសនា ឯព្រះបាទភវវរ្ម័នជាអ្នកកាន់សាសនាព្រះឥសូរ ។ យ៉ាងណាមិញបូជនីយេសក៍ចិនឈ្មោះ យីស៊ីងបានសរសេរនៅចុង ស.វ.ទី ៧ថា : "ពីដើមនៅហ្វូណានព្រះធម៌

បានចំរើនលូតលាស់ហើយផ្សព្វផ្សាយទៅគ្រប់ទិសទី តែឥឡូវនេះមានព្រះរាជាកំណាចមួយអង្គបានបំផ្លាញចោលអស់ ឯព្រះសង្ឃតែមួយអង្គក៏គ្មានដែរ " ។ ប្រសិនបើគេប្រៀបធៀបភាពរុងរឿងនៃព្រះពុទ្ធសាសនានៅអាណាចក្រភ្នំ នៅស.វ.ទី ៥-៦ និងសិលាចារឹករបស់ព្រះបាទភវវរ្ម័ន និងស្តេចសោយរាជ្យតៗមកទៀតដែលសុទ្ធតែនិយមសាសនាព្រះឥសូរនោះ គេអាចសន្និដ្ឋានថា "ព្រះរាជាកំណាច " គឺគ្មានអ្នកណាក្រៅពីព្រះបាទភវវរ្ម័នឡើយ ។

- លោក Bernard Philippe Groslier យល់ផ្សេងពីនេះទៅវិញ ។ ក្នុងសៀវភៅ Ankor ,Hommes et pierres លោកបានបញ្ចេញយោបល់របស់លោកថា : " មហន្តរាយដែលបណ្តាមកពីទឹកជំនន់បានបំផ្លាញទីក្រុងនិងប្រពន្ធ័បញ្ចូលទឹកក្នុងស្រែ ហើយបង្ខំអោយប្រជារាស្ត្រភៀសខ្លួនទៅរស់នៅត្រង់ដីខ្ពស់នៅភាគខាងជើងពេលនោះកូសាំងស៊ីនក៏ក្លាយទៅជាវាលល្បប់មួយស្ងាត់ជ្រងំ ។ ប្រហែលជាឆ្លៀតឱកាសនេះហើយដែលព្រះបាទភវវរ្ម័នបាទវាយយកប្រទេសហ្វូណននៅប្រមាណឆ្នាំ៥៥០ដើម្បីបង្កើតរាជាណាចក្រខ្មែរ " ។

ចំពោះយើងផ្ទាល់ យើងយល់ថាប្រសិនជានៅពេលនោះមានទឹកជំនន់ដូចលោក Groslier ពោលមែននោះ បុព្វហេតុទាំង៣ខាងលើនេះ គឺទំនាស់ក្នុងរឿងរាជបល្ល័ង្ក ទំនាស់ខាងសាសនា និង មហន្ត-រាយធម្មជាតិជាបុព្វហេតុបង្គ្រប់ទៅវិញទៅមកក្នុងចម្បាំងរវាងចេនឡានិងអាណាចក្រភ្នំ ។

នៅពាក់កណ្តាលទី២នៃស.វ.ទី ៦ ព្រះបាទភវវរ្ម័ននិងប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាម **ចិត្រសេន** បានផ្តើមវាយលុកអាណាចក្រភ្នំ ។ ក្នុងដំណាក់កាលដំបូងនៃចម្បាំងរវាងគ្នាឯងនេះ ទ័ពខាងចេនឡាបានសំរុកចូលយ៉ាងហោចណាស់ក៏ដល់ក្រចេះនៅលើច្រាំងខាងកើតនៃទន្លេមេគង្គ ដល់បុរីរម្យនៅចន្លោះទន្លេមូលនិងជួរភ្នំដងរែក និងដល់មង្គលបុរីនៅខាងលិចបឹងទន្លេសាប នេះបើគេផ្អែកទៅលើសិលាចារឹក របស់ព្រះបាទភវវរ្ម័ននិងប្អូនជីដូនមួយរបស់ព្រះអង្គ ។ នៅចំពោះមុខអាសន្ននេះទ័ពខាងអាណាចក្រភ្នំទំនងជាថយដៃជាង ក៏លើករាជធានីចេញពីវ្យាធបុរទៅតាំងនៅទិសខាងត្បូងគឺនៅត្រង់**ណរវរនគរ** (នរវរនគរ) ដែលអ្នកប្រវត្តិសាស្ត្រយល់ថាត្រូវនឹងតំបន់ អង្គរបុរីក្នុងខេត្តតាកែវសព្វថ្ងៃនេះ ព្រោះនៅកន្លែងនោះមានវត្ថុបុរាណជាច្រើន ឯឈ្មោះ **អង្គរបុរី**សោតទៀតក៏បង្ហាញថា ទីនោះជា រាជធានីចាស់មួយដែរ ។

## ១. ព្រះបាទភវវរ្ម័នទី១ (៥៩៨)

រហូតដល់ពេលនេះ គេបានរកឃើញសិលាចារឹកសំស្ក្រឹតពីរផ្ទាំងរបស់ព្រះបាទភវវរ្ម័ន : មួយផ្ទាំងគឺសិលាចារឹកភ្នំបន្ទាយនាងនៅតំបន់មង្គលបុរីខេត្តបាត់ដំបង ដែលនិយាយពីការកសាងលិង្គព្រះឥសូរមួយផ្ទាំងទៀតគេរកឃើញនៅស៊ីថេបក្នុងដែនដីសៀម បាននិយាយពីការកសាងផ្ទាំងសិលាចារឹក

នោះ ក្នុងឱកាសដែលព្រះអង្គបានឡើងកាន់អំណាច ។ តាមគេប៉ាន់ស្មានមើលទៅរាជធានីរបស់ព្រះអង្គ (ភវបុរ) ប្រហែលជាស្ថិតនៅត្រង់ម្តុំអំពិលរលំ ចម្ងាយ ៣០គ.ម.ទិសពាយព្យ័ក្រុងកំពង់ធំ ។ ក្នុងរជ្ជកាលរបស់ព្រះអង្គ ប្អូនជីដូនមួយរបស់ព្រះអង្គចិត្រសេនបានកសាងផ្ទាំងសិលាចារឹកសំស្ក្រឹតខ្លះៗជាច្រើន និយាយពីការកសាងលិង្គ នៅតាមបណ្តោយទន្លេមេគង្គ ក្នុងតំបន់ក្រចេះ ស្ទឹងត្រែង និងនៅខាងលិចបុរីរម្យ ។

គេមិនដឹងច្បាស់ថាព្រះបាទភវវរ្ម័នបានសោយរាជ្យប៉ុន្មានឆ្នាំទេ គេគ្រាន់តែបានដឹងថាព្រះអង្គនៅសោយរាជ្យនៅឡើយនៅឆ្នាំ ៥៩៨ ។ ក្រោយពីព្រះអង្គសោយទីវង្គតទៅ ប្អូនជីដូនមួយព្រះអង្គបានឡើងសោយរាជ្យស្នងនៅប្រមាណឆ្នាំ៦០០ ។

## ២. ព្រះបាទមហេន្ទ្រវរ្ម័ន (៦០០)

ពេលឡើងសោយរាជ្យ ព្រះបាទចិត្រសេនទ្រង់យកព្រះនាមសំរាប់រាជ្យថា **មហេន្ទ្រវរ្ម័ន** ។ ព្រះអង្គទ្រង់បានសាងសិលាចារឹកផ្សេងទៀតនៅត្រង់ពាមទន្លេមូលនិងនៅសុរិន្ទ និយាយពីការកសាងលិង្គ **គិរិស** និងរូបគោ **នន្ទិន** ក្នុងឱកាសដែលព្រះអង្គបានធ្វើសង្គ្រាមវាតទឹកដី ជាបន្តពីព្រះរៀម ឆ្ពោះទៅទិសខាងលិច និងខាងត្បូង ។ នៅខាងកើតព្រះអង្គទ្រង់បានបញ្ជូនរាជទូតឈ្មោះ **សិង្ហទេវ** ដែលជាមន្ត្រីរបស់ព្រះរៀម (ក្រោមសិលាចារឹកអង្គជំនិត) អោយទៅចងស្ពានមេត្រីជាមួយប្រទេសចាម្ប៉ា ។

## ៣. ព្រះបាទឦសានវរ្ម័នទី១ (៦១៦-៦៣៥)

ព្រះបាទឦសានវរ្ម័នជាបុត្រព្រះបាទមហេន្ទ្រវរ្ម័ន ។ ព្រះអង្គឡើងសោយរាជ្យនៅឆ្នាំ៦១៦ហើយសោយទីវង្គតទៅនៅឆ្នាំ៦៣៥ ។ ព្រះអង្គទ្រង់បានបន្តសង្គ្រាមវាយយកអាណាចក្រភ្នំដែលព្រះបិតា និងព្រះបិតុលាបានផ្តើមធ្វើនៅឆ្នាំ៥៥០ ។ សិលាចារឹកជាច្រើនបានបញ្ជាក់ពីជោគជ័យរបស់ព្រះអង្គនៅកំពង់ចាម ព្រៃវែង កណ្តាល តាកែវ និង ចន្ទបូរ ។ ព្រះអង្គទ្រង់បានបញ្ចប់សង្គ្រាមជាមួយអាណាចក្រភ្នំ ដោយវាយយកបានរាជធានី **នរវរនគរ** (អង្គរបុរី-តាកែវ)ប្រមាណនៅឆ្នាំ៦៣០ ។

ព្រះអង្គបានតាំងរាជធានីនៅ **ឦសានបុរ** ដែលគេថាត្រូវនឹងរមណីយដ្ឋាន **សម្បូណ៌ព្រៃគុក**នៅខាងជើងខេត្តកំពង់ធំ ព្រោះនៅទីនោះគេឃើញមាន សិលាចារឹករបស់ព្រះអង្គជាច្រើន ។ ក្នុងរជ្ជកាលរបស់ព្រះអង្គទំនងជាមានផ្តើមការកសាងនៅភ្នំបាយ៉ង់ក្នុងខេត្តតាកែវ ។

ដើម្បីរឹតចំណងមិត្តភាពជាមួយប្រទេសជិតខាង ព្រះអង្គទ្រង់បានបញ្ជូនទូតទៅ ប្រទេសចិនច្រើនលើកគឺ នៅឆ្នាំ៦១៦ ៦២៣និង៦២៨និងរៀបរាជាភិសេកបុត្រីព្រះអង្គព្រះនាម **សាវ៉ានិ** ជាមួយនឹងព្រះអង្គម្ចាស់ចាមមួយអង្គ ។

គួរគប្បីសង្កេតថា ឆៀតឱកាសដែលអំណាចកណ្ដាលចុះខ្សោយដោយមានវិបត្តិរាជវង្ស ហើយបន្ទាប់មកដោយមានការវាយលុករបស់ចេនឡា មានរដ្ឋជាច្រើនបានរើបំរាស់រួចពីអំណាចត្រួតត្រារបស់អាណាចក្រភ្នំ ។ គឺក្នុងកាលៈទេសៈនេះហើយដែលគេឃើញរដ្ឋ **ទ្វារវតី** របស់ជនជាតិមនមានរូបរាងច្បាស់ឡើងនៅត្រង់វាលទំនាបខាងក្រោមនៃទន្លេមេណាម និងរដ្ឋចាមរបស់ពួក ក្រកូលដើមដូង (នរិកេសវង្ស) មានរូបរាងច្បាស់ឡើងដែលនៅត្រង់ម្ដុំ **កៅឋារះ** (ញ៉ាត្រាង) និង **បាណ្ឌុរង្គ** (ផានរ៉ាង) ហើយក្លាយជាគូប្រឆាំងនឹងលីន យី របស់ពួកត្រកូលដើមស្លា (ក្រមុកវង្ស) ដែលបានកើតឡើងតាំងតែពីឆ្នាំ១៩២ ។ ប្រហែលជាដោយសារស្ថានភាពបែបនេះ ហើយបានជាគេឃើញ ព្រះរាជាចេនឡា ជាបន្តបន្ទាប់គ្នាបានធ្វើនយោបាយសន្តិភាពដោយចងស្ពានមេត្រីជាមួយនឹងលីនយី ។

គួរគប្បីសង្កេតម្យ៉ាងទៀតថាក្នុងពេលបរាជ័យទាំងស្រុង អធិរាជអាណាចក្រភ្នំដែលបានលើករាជធានីពីវ្យាធបុរៈទៅតាំងនៅនរវរនគរនោះ ប្រហែលជាបានភៀសព្រះអង្គទៅគង់នៅលើជ្រោយមលយូ ។ ដូច្នេះហើយបានជានៅពេលក្រោយៗមកទៀត មានព្រះរាជាខ្មែរយាងមកពីទីនោះ ហើយមកសោយរាជ្យនៅអង្គរវិញដូចជាករណីរបស់សូរ្យវរ្ម័នទី១ជាដើម តែបើតាមឯកសារខ្លះថាស្ដេចអង្គនេះមានបិតាជាជ្វា ឯមាតាជាក្សត្រីខ្មែរនៅអង្គរទៅវិញ ។

## គ. ការបែងចែកប្រទេសចេនឡា

### ១. ព្រះបាទភវវរ្ម័នទី២ (៦៣៩)

ព្រះបាទឦសានវរ្ម័នទី១ទំនងជាគ្មានបុត្រទេ ។ ស្ដេចដែលសោយរាជ្យតពីព្រះអង្គ គឺព្រះបាទភវវរ្ម័នទី២ដែលគេមិនដឹងថាជាប់ញាតិខាងណាជាមួយព្រះអង្គទេ ។ ព្រះបាទភវវរ្ម័នទី២ ទ្រង់បានបន្សល់ទុកនូវសិលាចារឹកមួយចុះកាលកំណត់នៅឆ្នាំ៦៣៩ ហើយដែលគេរកឃើញនៅតំបន់តាកែវ ។ តាមគេប៉ាន់ស្មានមើលទៅផ្ទាំងសិលាចារឹកនៅភ្នំបាយ័ង់និងនៅភ្នំព្រះវិហារ កំពង់ឆ្នាំងក៏ជាស្នាព្រះហស្តរបស់ព្រះអង្គដែរ ។

### ២. ព្រះបាទជ័យវរ្ម័នទី ១ (៦៥៧-៦៨១ ?)

ព្រះបាទជ័យវរ្ម័នទី១ជាបុត្រព្រះបាទភវវរ្ម័នទី ២ ។ ព្រះអង្គទំនងជាឡើងសោយរាជ្យនៅមុនឆ្នាំ ៦៥៧ ។ ក្នុងវិស័យកសាង ក្នុងរជ្ជកាលរបស់ព្រះអង្គគេឃើញមានសិលាចារឹកជាច្រើននិងការសង់ប្រាសាទនៅតំបន់វ្យាធបុរ និងវត្តភូ ។ ក្នុងវិស័យនយោបាយក្រៅប្រទេស ព្រះអង្គទ្រង់បានបញ្ជូនទូតទៅប្រទេសចិន តែគេមិនដឹងច្បាស់ពីកាលកំណត់នៃព្រឹត្តិការណ៍នេះទេ ។

តាមការប៉ាន់ស្មាន ព្រះបាទជយវរ្ម័នទី១ប្រហែលសោយទិវង្គតទៅនៅក្រោយឆ្នាំ៦៨១ ។ ព្រះអង្គពុំមានបុត្រទេ ដោយហេតុនេះហើយទើបបុត្រីរបស់ព្រះអង្គនាម **ជយទេវី** ឡើងសោយរាជ្យស្នង ។ ព្រះនាងនៅគ្រប់គ្រងរដ្ឋរហូតដល់ឆ្នាំ៧១៣តែអំណាចរបស់ព្រះនាងពុំមានមូលដ្ឋានមាំទាំឡើយ ព្រោះក្នុងអត្ថបទសិលាចារឹកមួយនៅបារាយទឹកថ្លា ព្រះនាងទ្រង់បានត្អូញត្អែរពី "ភាពច្របូកច្របល់ក្នុងចិត្តគំនិត និងពីទុក្ខវេទនាក្នុងគ្រាកើតកលិយុគ " ។

តើកំសោយនៃអំណាចកណ្តាលដែលស្ថិតនៅក្នុងកណ្តាប់ដៃស្ត្រីនេះហើយ ឬ ដែលជាបុព្វហេតុនៃការបែងចែកចេនឡាធំ ? យ៉ាងណាមិញ បើតាមពង្សាវតារចិន ប្រទេសចេនឡាត្រូវបែងចែកជាពីរនៅខាងដើម ស.វ.ទី៨(៧០៦) :"ភាគខាងជើងដែលគេហៅថា **ចេនឡាដីគោក** ជាតំបន់ពោរពេញដោយភ្នំនិងជ្រលងភ្នំ ឯភាគខាងត្បូងដែលគេហៅថា **ចេនឡាទឹកលិច** ជាតំបន់សម្បូណ៌ដោយបឹងបួរហើយមានសមុទ្រព័ទ្ធជុំវិញ " ។ បើតាមការស្រាវជ្រាវ ចេនឡាដីគោកមានវិសាលភាពលាតសន្ធឹងទៅលើប្រទេសឡាវភាគកណ្តាលនិងភាគខាងត្បូងសព្វថ្ងៃ ឯចេនឡាទឹកលិចគ្របដណ្តប់ទៅលើអាងទន្លេមេគង្គចាប់ពីល្បាក់ទឹកខោនរហូតដល់សមុទ្រ ។

## ៣. ចេនឡាទឹកលិច

គួរគប្បីបញ្ជាក់ថាចេនឡាទឹកលិចក៏មិនអាចថែរក្សាឯកភាពអោយបានយូរអង្វែងទេៈ រដ្ឋនេះត្រូវបែងចែកជាក្សត្របុរីតូចៗតទៅទៀត យ៉ាងតិចណាស់ក៏មានចំនួនប្រាំហើយក្សត្របុរីដែលគេដឹងឈ្មោះពិតប្រាដកគឺ **អនិន្ទិតបុរ** ដែលគេមិនស្គាល់ទីតាំងច្បាស់លាស់និង **សម្ភុបុរ** គឺសំបូរនៅលើត្រើយ ខាងឆ្វេងទន្លេមេគង្គក្នុងខេត្តក្រចេះ ។ នៅខាងដើមស.វ.ទី៨ព្រះអង្គម្ចាស់**បុស្ករាក្ស** ដែលមានដើមកំណើតនៅអនិន្ទិតបុរបានយាងទៅសោយរាជ្យនៅសម្ភុបុរ(៧២៣)ជាទីដែលព្រះអង្គបានបន្សល់ទុកសិលាចារឹកមួយផ្ទាំងចុះកាលកំណត់៧១៦ នៅត្រង់ប្រាសាទ **ព្រះធាតុកូនពីរ** ។ ព្រះអង្គម្ចាស់នេះមានជាប់ខ្សែញាតិទៅនឹងព្រះបាទ **ពាលាទិត្យ** ដែលបានសោយរាជ្យនៅអនិន្ទិតបុរ ហើយដែលបានអះអាងថាព្រះអង្គជាកូនចៅរបស់ព្រះបាទ **កៅណ្ឌិន្យ** និងព្រះនាង **នាគីសោមា** ហើយដែលក្រោយមកទៀត ព្រះរាជាសោយរាជ្យនៅអង្គរទ្រង់បានចាត់ទុកថាជាចំណងភ្ជាប់ព្រះអង្គទាំងឡាយទៅនឹងស្ថាបនិកនៃបឋមវង្សនៃអាណាចក្រភ្នំ ។ត្រង់នេះយើងអាចយកធ្វើជាអំណះអំណាងមួយសំរាប់ឆ្លើយតបចំពោះជនណាដែលបដិសេធថា អាណាចក្រភ្នំពុំមែនជារដ្ឋខ្មែរដំបូង ។ ចុះហេតុអ្វីបានជាអធិរាជអង្គរដែលបានវាយឈ្នះអាណាចក្រភ្នំបែរជាខិតខំភ្ជាប់ខ្សែស្រឡាយរបស់ព្រះអង្គទៅនឹងព្រះរាជាអាណាចក្រភ្នំ ដែលជាអ្នកចាញ់ទៅវិញ ? នេះមិនគឺមកតែពីមនុស្សតាំងតែពីសម័យអាណាចក្រភ្នំរហូតដល់សម័យអង្គរមានពូជអំបូរជាតិសាសន៍តែមួយទេឬ?

ព្រះបាទពាលាទិត្យទំនងជាបានកសាងក្រុង **ពាលាទិត្យបុរ** ដែលជនជាតិចិនចាត់ទុកថា ជារាជធានីពិតប្រាកដករបស់ចេនឡាទឹកលិច(ប៉ូឡូទីប៉ូ) ។

ក្នុងពាក់កណ្តាលទី២នៃស.វ.ទី៨នៅចេនឡាទឹកលិច មានការកសាងសិលាចារឹកជាច្រើន ជាពិសេសនៅតំបន់សម្បុរដែលគេបានរកឃើញមួយចុះកាលកំណត់ ៧៧០ (ព្រះធាតុព្រះស្រី-ត្បូងឃ្មុំ ) និង មួយទៀតចុះកាលកំណត់ ៧៨១(ល្មើកស្រត-ក្រចេះ)ទាំងនេះសុទ្ធតែជាស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី១ស្ទួន (ដាក់លេខទី១ស្ទួនគឺដើម្បីកុំអោយពិបាករុះរើលេខព្រះរាជាអង្គរពីជ័យវរ្ម័នទី២ដល់ទី៩) ។ ក្រៅពីនេះ គេបានរកឃើញសិលាចារឹកមួយផ្ទាំងទៀតចុះកាលកំណត់ ៧៩១នៅប្រាសាទ **តាគាម** ក្នុងខេត្តសៀមរាប ។ គេចាត់ទុកសិលាចារឹកនេះ ថាជាសក្ខីភាពមួយចាស់ជាងគេនៃព្រះ **ពុទ្ធសាសនាមហាយាន** នៅស្រុកខ្មែរ ព្រោះឯកសារនេះបាននិយាយពីការកសាងបដិមាព្រះពោធិសត្វ **លោកេស្វរៈ** ជាពោធិសត្វបានគេនិយមគោរពបូជាជាងគេនៅស្រុកខ្មែរយើង ។ ក្នុងសិល្បៈចម្លាក់បុរាណសិល្បករខ្មែរច្រើនឆ្លាក់រូបពោធិសត្វនេះជារូបបុរសមានវ័យក្មេងមានព្រះហស្ត៤កាន់ផ្កាឈូក ខ្សែផ្កាំ គម្ពីរ និងដបទឹក (សូមកុំច្រឡំនិងព្រះវិស្ណុដែលមានព្រះហស្ត៤ដែរ តែកាន់ផ្កាឈូកកងចក្រ ក្រទា និងសង្ខ) ។ នៅលើព្រះសិររបស់ព្រះអង្គមានរូបព្រះពុទ្ធអាមិតាភៈ ។

## ៤. ចេនឡាជីគោក

ប្រវត្តិចេនឡាជីគោកគេមិនសូវដឹងច្បាស់ទេ ព្រោះហាក់ដូចជានៅដាច់ស្រយាលពីការទៅមករបស់អ្នកដំណើរចិនពេក ។ ទោះបីយ៉ាងនេះក៏ដោយ ក៏គេបានដឹងថាក្នុងសម័យនោះនយោបាយក្រៅប្រទេសចេនឡាជីគោកបានបញ្ជូនទូតទៅប្រទេសចិននៅឆ្នាំ ៧១៧ ។ ម្យ៉ាងទៀត នៅឆ្នាំ ៧២២ចេនឡាជីគោកបានលើកទ័ពទៅជួយមេទ័ពយួនឈ្មោះ **ម៉ៃហាក់ដេ** (mai hac-dè) ដែលបានបះឡើងប្រឆាំងនឹងការជិះជាន់របស់ពួកចិនក្នុង **រាជវង្សថាំង** (៦១៨-៩០៧) ។ យ៉ាងណាមិញ នៅឆ្នាំ៦២១ ស្តេច **កៅត** នៃរាជវង្សនេះបានបញ្ជាអោយមេទ័ពឈ្មោះ **ខូវ៉ា** លើកទ័ពទៅវាយយក **យ៉ាវចូវ** (ឈ្មោះស្រុកយួននៅសម័យនោះ)ដែលក្រោយមកទៀតគឺនៅឆ្នាំ៦៧៩ស្តេច **កៅតុខ**បានផ្លាស់ឈ្មោះទៅជា **អាណ្ណាមដូហូតូ** (ប្រទេសជាអាណាព្យាបាល)វិញ (31) ។ គឺក្នុងករណីនេះហើយដែលមេទ័ពយួនឈ្មោះម៉ៃហាក់ដេ បានបះឡើងប្រឆាំងនឹងចិនដោយចងសម្ព័ន្ធមិត្តជាមួយចេនឡានិងចាម្ប៉ា ។ គួរគប្បីជ្រាបថា នេះគឺជាលើកទីមួយហើយដែលមានប្រើពាក្យអាណ្ណាមក្នុងប្រវត្តិសាស្ត្រយួន ។

នៅពាក់កណ្តាលទី ២នៃស.វ.ទី ៨ចេនឡាជីគោកទំនងជាត្រូវចិនហៅថា **ទិនតាន**ថែមទៀត ។ នៅឆ្នាំ៧៥៣មានការបញ្ជូនទូតទៅប្រទេសចិនក្រោមព្រះរាជកិច្ចដឹកនាំរបស់ព្រះរាជបុត្រនៃព្រះរាជា

នៅឆ្នាំ ៧៥៤ ព្រះរាជបុត្រអង្គដដែលឬអង្គមួយផ្សេងទៀតបានលើកទ័ពទៅជួយចិនក្នុងការវាយលុកយកតំបន់ណាន ឆាវ ។ នៅឆ្នាំ ៧៧១ និងឆ្នាំ ៧៩៩ មានការបញ្ជូនទូតទៅប្រទេសចិនទៀត ។ រាជធានីចេនឡាដីគោកទំនងជាស្ថិតនៅត្រង់ម្តុំមជ្ឈមណ្ឌលនៃចេនឡាដើម ហើយព្រះរាជាដែលមានមហិទ្ធិឫទ្ធិជាងគេទំនងជាព្រះបាទ **ជយសិទ្ធវរ្ម័ន** ព្រោះគេបានរកឃើញសិលាចារឹកមួយផ្ទាំងរបស់ព្រះអង្គនៅម្តុំ **នគររាជសីមា** ក្នុងដីសៀមសព្វថ្ងៃ ។

## ឃ. ចេនឡាក្រោមអំណាចត្រួតត្រារបស់ជ្វា

ប្រទេសខ្មែរនៅស. វ. ទី៨ ជាសម័យមួយដែលគ្មានស្ថិរភាពខាងនយោបាយ ព្រោះតែមានការបែកបាក់ផ្ទៃក្នុងយ៉ាងតំណំ ។ នេះហើយជាហេតុមួយអោយជាតិជិតខាងមើលងាយ ដោយហ៊ានលូកដៃចូលកកូរក្នុងកិច្ចការផ្ទៃក្នុងទៀតផង ។

យ៉ាងណាមិញ នៅស. វ. ទី ៨ ពួកចោរសមុទ្រជាតិជ្វាដែលជិះសំពៅធំៗបានចូលមកវាតត្បាតឆ្នេរសមុទ្រនិងតាមទន្លេនៃអាស៊ីអគ្នេយ៍ដីគោកក្នុងគោលបំណង ឆក់ ប្លន់យកទ្រព្យសម្បត្តិតាមទំនើងចិត្ត ។ ពួកចោរសមុទ្រដែលហ៊ានមកឈ្លានពានដូច្នេះបាន ព្រោះតែនៅពេលនោះ រាជវង្ស **សៃលេន្ទ្រ** ដែលសោយរាជ្យនៅកោះជ្វាហើយដែលជារាជវង្សស្ថាបនិកប្រាសាទ **បូរូបុឌួ** ដ៏ល្បីល្បាញនោះផ្សព្វផ្សាយឥទ្ធិពលរបស់ខ្លួនទៅលើអាស៊ីអគ្នេយ៍ទាំងមូល ។

នៅឆ្នាំ ៧៧៤ និង ៧៨៧ ពួកចោរជ្វា ក្រោយពីវាយបានកោះត្រឡាចហើយតាំងជាមូលដ្ឋាន បានលើកគ្នាទៅវាតត្បាត ឆ្នេរសមុទ្រប្រទេសចាម្ប៉ា ។ គឺនៅពេលជាមួយគ្នានេះហើយដែលពួកចោរនោះបានចូលមកវាតត្បាតចេនឡាទឹកលិចដែរ ដោយធ្វើដំណើរបញ្ច្រាសឡើងតាមទន្លេមេគង្គ មកដល់សម្ភុបុរ ដុតបំផ្លាញទីក្រុង ឡោមព័ទ្ធរាជវាំង ចាប់បានព្រះរាជាព្រះនាម **មហីបតិវរ្ម័ន** ជាបុត្រព្រះបាទ **រាជេន្ទ្រវរ្ម័ន** កាត់យកព្រះសិរហើយយកទៅប្រទេសជ្វា (32) ។ ចំពោះការឈ្លានពានរបស់ជ្វាមកលើក្សត្របុរីមួយរបស់ចេនឡាទឹកលិចនេះ មានមតិខ្លះយល់ថា ជាការទាមទារយកកេរមត៌ករបស់ដូនតាខ្លួន ព្រោះពួក **សៃលេន្ទ្រ** ធ្លាប់បានប្រកាសខ្លួនថាជា "**ស្តេចភ្នំ**" (សៃលេន្ទ្រ) ដែលជាឋានន្តនាមរបស់ព្រះរាជាអាណាចក្រភ្នំនេះឯង ។

ចំពោះការតាំងអំណាចអធិរាជភាព (Suzeraineté) របស់ពួកសៃលេន្ទ្រលើប្រទេសខ្មែរនេះ ឈ្មួញអារ៉ាប់ម្នាក់ឈ្មោះ **សូឡៃម៉ាន់** នៅស. វ. ទី១០ បាននិយាយថា : ថ្ងៃមួយព្រះរាជាខ្មែរមានព្រះបំណងចង់ឃើញព្រះសិរនៃមហារាជក្រុង Zabag កាត់ដាក់លើថាសមួយ ។ ដំណឹងនេះក៏ឮដល់មហារាជ : ព្រះអង្គក៏លើកទ័ពជើងទឹកចូលមកវាយប្រទេសខ្មែរ ចាប់បានព្រះរាជាខ្មែរហើយបញ្ជាអោយកាត់ព្រះសិរ ។

លុះត្រឡប់ទៅដល់ព្រះនគរវិញហើយ មហារាជទ្រង់អោយយកព្រះសិរនោះទៅលាងស្អាត យកអប់ទុកក្នុងភាជន៍មួយរួចទ្រង់អោយបញ្ជូនមកថ្វាយចំពោះព្រះរាជាដែលបានឡើងសោយរាជ្យជាតំណតមក ។ ចាប់តាំងពីពេលនោះមក នៅរៀងរាល់ព្រឹកព្រះរាជាខ្មែរត្រូវបែរព្រះភក្ត្រឆ្ពោះមកក្រុង Zabag ដើម្បីធ្វើគារវកិច្ចចំពោះព្រះមហារាជក្រុងនេះ (សេចក្តីស្រង់តាមអត្ថបទបោះពុម្ពផ្សាយ ដោយជនអារ៉ាប់ម្នាក់ទៀតឈ្មោះ Abou Zayd Hassan នៅប្រមាណឆ្នាំ ៩២៦) ។

រឿង ដែលតំណាលដោយឈ្មួញអារ៉ាប់ខាងលើនេះទោះបីមានលក្ខណៈ ជារឿងព្រេងក៏ដោយ ក៏មានលក្ខណៈស្របនឹងការពិតខ្លះដែរ : គឺតំណាងអំណាចរបស់ជ្វាមកលើប្រទេសខ្មែរយើង ហើយដែលមានការបញ្ជាក់ពីសិលាចារឹកស្តុកកក់ធំនៅពេលក្រោយមកទៀត ។

## ១. អរិយធម៌ខ្មែរសម័យចេនឡា

ចំពោះសម័យចេនឡាក៏ដូចជាសម័យអាណាចក្រភ្នំដែរ ពត៌មានដែលទាក់ទងនឹងវប្បធម៌-អរិយធម៌សុទ្ធតែបានមកពីប្រភពចិនស្ទើរតែទាំងអស់ ។ ចំពោះចេនឡានេះ យើងបានពឹងផ្អែកទៅលើពង្សាវតារស៊្វី (Souei) ដែលបានកត់ត្រារឿងរ៉ាវទាក់ទងនឹងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ហើយដែលលោក **ម៉ាត្វនលិន** បានចម្លងដាក់ទាំងស្រុងក្នុងសៀវភៅ "ការសិក្សាពីប្រជារាស្ត្រក្រៅប្រទេសចិន" របស់លោកនៅស.វទី១៣ ។

### ១. ជីវភាពសង្គម : លក្ខណៈមនុស្ស - ការរស់នៅ ទំនៀមទំលាប់

មនុស្សនៅសម័យនោះ មានមាឌតូចហើយសម្បុរខ្មៅ ដូចមនុស្សនៅសម័យអាណាចក្រភ្នំដែរ ប៉ុន្តែស្រីៗភាគច្រើនមានសម្បុរស(នេះប្រហែលជាមកពីនៅក្នុងម្លប់មិនចេញប្រកបការងារខាងក្រៅដូចប្រុសទេដឹង?) ។ ទាំងប្រុសទាំងស្រីសុទ្ធតែបួងសក់ ហើយពាក់រយ៉ាថែមទៀត ។ លក្ខណៈរូបរាងកាយទាំងនេះឃើញថាដូចពួកខ្មែរលើដែលរស់នៅលើខ្ពង់រាបសព្វថ្ងៃច្រើន ។ ឯកសារចិនបានបញ្ជាក់ទៀតថាពួកនេះមានគំនិតវាងវៃ ហើយមានមាឌមាំមួនទៀតផង ។ គេចាត់ទុកដៃស្តាំថាបរិសុទ្ធ ឯដៃឆ្វេងថាមិនបរិសុទ្ធ ។ រៀងរាល់ព្រឹកគេតែងធ្វើការលុបលាង ចាក់ធ្មេញរួចអានសៀវភៅ(?)ឬសូត្រធម៌ ។ មុនពេលទទួលទានអាហារ គេតែងលុបលាងសាជាថ្មី លុះទទួលទានរួចហើយគេចាក់ធ្មេញហើយគេ សូត្រធម៌ជាថ្មីថែមទៀត ។ ក្នុងម្ហូបអាហារគេចូលចិត្តប្រើទឹកដោះគោស្ករគ្រាប់ល្ងិត បាយ និង millet (?) ។

សិលាចារឹកអោយដឹងថា គេនិយមរាប់ញាតិដោយយកខ្សែតាមម្តាយ ។ ក្នុងរឿងជ្រើសរើសគូស្រករ គឺពួកប្រុសៗទៅដណ្តឹងស្រី : ត្រង់នេះឃើញថា មានការវិវត្តិប្លែកពីសម័យមុនដែលពួកស្រីៗទៅ

ដណ្ដឹងប្រុសៗ ។ មុនដំបូងខាងប្រុសត្រូវលើកជំនួនទៅខាងគ្រួសារស្រីដែលខ្លួនពេញចិត្ត បន្ទាប់មកខាងស្រីត្រូវជ្រើសរើសថ្ងៃមង្គលដើម្បីនាំកូនស្រីទៅផ្ទះខាងប្រុស តាមរយៈមេអណ្ដើកម្នាក់ ។ គ្រួសារទាំងសងខាងស្ថិតនៅក្នុងផ្ទះអស់រយៈពេល៨ថ្ងៃ ដោយពុំមានចេញទៅណាមកណា ហើយដោយមានអុជចង្កៀងទាំងយប់ទាំងថ្ងៃ ។ លុះពិធីមង្គលការចប់សព្វគ្រប់ហើយ កូនប្រុសទទួលមត៌កពីឪពុកម្ដាយបង្កើតរបស់ខ្លួន ហើយបែកផ្ទះទៅនៅដោយឡែក ។ ដល់ពេលឪពុកម្ដាយស្លាប់ទៅពួកកូនដែលនៅលីវអាចទទួលយកមត៌កដែលនៅសេសសល់ទាំងអស់ ប៉ុន្តែប្រសិនបើកូនទាំងនោះមានប្ដីប្រពន្ធហើយបានទទួលមត៌ករួចហើយ នោះទ្រព្យដែលនៅសល់ត្រូវគេបញ្ជូនទៅក្នុងឃ្លាំងជាតិ ។

ក្នុងពិធីបុណ្យសព កូនទាំងឡាយរបស់សព ត្រូវអត់បាយ៧ថ្ងៃ ត្រូវកោរសក់ហើយត្រូវយំស្រែយ៉ាងខ្លាំង ។ ក្រុមគ្រួសារនៃសពដោយរួមនឹងព្រះភិក្ខុនិងភិក្ខុនីបានធ្វើក្បួនដង្ហែដោយមានច្រៀង(?) និងលេងភ្លេងផង ។ សពគេបូជាក្នុងបច្ឆាសង់ដោយឈើក្រអូប រួចគេរើសធាតុដាក់ក្នុងកោដ្ឋមាសឬប្រាក់ហើយយកទៅទំលាក់ចោលក្នុងទឹក ។ ពួកអ្នកក្រប្រើកោដ្ឋដីមានលាបពណ៌ផ្សេងៗ ។ មានខ្លះគ្រាន់តែយកសពទៅដាក់ចោលក្នុងព្រៃស្មសានអោយសត្វស៊ី ។

ទម្លាប់របស់អ្នកស្រុកម្យ៉ាងទៀតគឺ ពេលទៅណាមកណាមានពាក់អាវក្រោះនិងកាន់អាវុធ ហើយបើកាលណាមានរឿងបន្តិចបន្តួច គេក៏ប្រយុទ្ធបង្ហូរឈាមគ្នាភ្លាម ។

## ២. នយោបាយនិងរដ្ឋបាល

ចាប់តាំងពីរជ្ជកាលព្រះបាទឦសានវរ្ម័នទៅ រាជធានីតាំងនៅឦសានបុរ(ចិនហៅអ៊ីចូណា)ហើយមាន ២០០០០គ្រួសារ ។ នៅកណ្ដាលក្រុងមានសាលធំមួយ ជាទីដែលព្រះរាជាទ្រង់ប្រទានសវនាការនិងប្រជុំពួកមន្ត្រីសេនាបតី ។ ក្រៅពីរាជធានី នៅមានក្រុងចំនួន ៣០ទៀត ក្រុងនីមួយៗមានច្រើនពាន់គ្រួសារហើយត្រួតត្រាដោយអភិបាលម្នាក់ ។ ក្នុង៣ថ្ងៃម្ដងព្រះរាជាតែងយាងទៅកាន់សាលប្រជុំ ។ មន្ត្រីជាន់ខ្ពស់មាន៥នាក់: ទី១មានងារហៅតាមចិនថា Kou-lo-yeou ទី២ Siang-kao -ping ទី៣ Po-hoto-ling ទី៤ Cho-mo-ling ទី ៥ jan -lo-leou ។ រហូតមកដល់ពេលនេះ គេមិនទាន់រកឃើញថាគោរមងារដែលហៅតាមចិននេះត្រូវនឹងពាក្យខ្មែរជំនាន់នោះថាយ៉ាងម៉េចនៅឡើយទេ ។ ឯពួកមន្ត្រីតូចតាចវិញមានចំនួនច្រើនណាស់ ។

នៅចំពោះព្រះភក្ត្រព្រះរាជា ពួកមន្ត្រីត្រូវធ្វើគារវកិច្ចដោយអោនក្បាលដល់ដីបីដង ។ បើព្រះអង្គទ្រង់មានបន្ទូលហៅឬប្រើពួកមន្ត្រីត្រូវលុតជង្គង់រថទៅ ទៅអង្គុយជំកង់ជុំវិញព្រះរាជាដើម្បីពិភាក្សាពីកិច្ចការប្រទេសជាតិ ។ ចប់កិច្ចហើយគេត្រូវលុតជង្គង់សំពះសាជាថ្មីមុននឹងត្រឡប់ទៅវិញ ។ គេឃើញ

មានទាហានរាប់ពាន់នាក់ពាក់អាវគ្រោះ កាន់លំពែងឈរយាមគ្រប់ទីកន្លែង តាំងពីជុំវិញបល្ល័ង្ករហូតដល់ទ្វារទាំងឡាយ ។

ចំពោះការផ្ទេររាជសម្បត្តិ គឺមានតែបុត្រនៃអគ្គមហេសីទេទើបឡើងសោយរាជ្យបាន ។ នៅថ្ងៃប្រារព្ធពិធីអភិសេកព្រះរាជាថ្មី គេកាត់ម្រាមដៃច្រមុះនៃបុត្រឯទៀតៗ រួចយកទៅឃុំទុកនៅកន្លែងទីទៃៗពីគ្នា ដោយមិនអោយកាន់តំណែងអ្វីមួយសោះឡើយ ។

## ច. សកម្មភាពសេដ្ឋកិច្ច

ខ្មែរយើងធ្លាប់មានជោគជ័យក្នុងនយោបាយទឹកតាំងពីសម័យអាណាចក្រភ្នំមកម្ល៉េះ ។ ចូលមកដល់សម័យចេនឡា នយោបាយទឹកមានសភាពរីងរឹតតែប្រសើរឡើងថែមទៀត ជាហេតុញ៉ាំងអោយមានការកសាងទីក្រុងធំៗនៅក្បែរមាត់ស្ទឹង និងញ៉ាំងអោយកសិកម្មមានការរីកចំរើនលូតលាស់ជាលំដាប់ ។ ឧ.ក្រុងវ្លាសានបុរត្រូវបានកសាងនៅក្បែរស្ទឹងសែន ឯទឹកស្ទឹងនោះត្រូវបង្ហូរចូលក្នុងស្រះព័ទ្ធជុំវិញក្រុងនិងក្នុងអាងទឹកឯទៀតៗក្នុងផ្ទៃក្រុងៈ ធ្វើដូច្នេះ គេអាចមានទឹកប្រើប្រាស់គ្រប់គ្រាន់ ហើយមានលទ្ធភាពពង្រីកដីដាំដំណាំទៀតផង ។ បើតាមឯកសារចិនថាគេដាំស្រូវ seigle(?) mil (?) និង gros millet (?) ។ ចំពោះស្រូវ គេជឿថាមានពិតប្រាកដ ហើយតែចំពោះដំណាំឯទៀតៗគេមិនដឹងជាមានមែន ឬយ៉ាងណាទេ ។

## ឆ. វប្បធម៌

ក្រៅពីភាសាសំស្ក្រឹតដែលមានប្រើតាំងពីដើមរៀងមក នេះជាលើកដំបូងដែលគេឃើញមានប្រើភាសាខ្មែរបុរាណក្នុងសិលាចារឹកៈ សិលាចារឹកខ្មែរដំបូងដែលមានចុះកាលកំណត់ច្បាស់គឺ សិលាចារឹកអង្គរបុរី(៦១១) ។ ក្នុងផ្នែកអក្សរសិល្ប៍ សិលាចារឹកវាលកន្ទេលបាននិយាយថាគេសូត្រជារៀងរាល់ថ្ងៃនូវរឿងរាមាយណ រឿងមហាភារតិនិងគម្ពីរបុរាណ( A.Barth et A .Bergaigne ,Inscriptions Sanskrites du Cambodge , T .I .P. 30)

ក្នុងវិស័យសាសនា សិលាចារឹកបានអោយដឹងថា មានការគោរពបូជាចំពោះគណៈផ្សេងៗដែលបានរួមរស់ជាមួយគ្នា :

- គណៈសិវៈ **:**មានឋានៈជាសាសនាផ្លូវការព្រោះព្រះរាជាទាំងអស់តាំងតែពីព្រះបាទភវវរ្ម័នទី១ និងប្អូនជីដូនមួយរបស់ព្រះអង្គចិត្រសេន សុទ្ធតែបានធ្វើការកសាងលិង្គព្រះឥសូរជាច្រើន ដូចយើងបានឃើញរួចមកហើយ ។ ចំពោះព្រះរាជាខ្លះដូចជាជ័យវរ្ម័នទី១ជាដើម ទំនងជាមានប្រើមរណនាមរួចទៅ

ហើយ ។ យ៉ាងណាមិញសិលាចារឹកឆ្នាំ៧១៣ដែលនិយាយថា "ព្រះរាជាដែលយាងទៅកាន់សិវបុរ " ប្រហែលជាចង់ដៅចំពោះព្រះអង្គនេះឯង ។ ចំណែកឯព្រះមរណនាម **ឥន្ទ្រលោក** ដែលមានចារឹកក្នុងសិលាចារឹក ៨០៣ក៏ទំនងជាដៅចំពោះព្រះបាទបុស្ករាក្ស ដែលគេយល់ថាបានយាងទៅសោយរាជ្យនៅសម្ភុបុរ នៅពេលដែលរាជបល្លង្កនៅទីនោះនៅទំនេរហើយដែលព្រះអង្គប្រើកម្លាំងផង ។ ក្រៅពីការគោរពបូជាលិង្គ នៅមានគណៈមួយទៀតដែលគេគោរពព្រះឥស្វរដែរ គឺគណៈបាសុបត ។

- **គណៈវិស្ណុ** ៖ មិនសូវមានគេនិយមច្រើនទេ ។ មានការគោរពចំពោះគណៈបញ្ចរាត្រ ។

- **ហរិហរ** ៖ គេគោរពព្រះហរិហរជាបន្តពីសម័យអាណាចក្រភ្នំមក ។ មានរូបបដិមាហរិហរយ៉ាងល្អវិចិត្រហើយមានរាងសង្ហាថែមទៀតដូចជាហរិហរប្រាសាទអណ្តែត (ស្ទោង-កំពង់ធំ)ជាដើម ។ តែក្រោយពីនេះគេពុំឃើញ មានការគោរពហរិហរទៀតឡើយ ។

- **ពុទ្ធសាសនា** ៖ មិនបាត់បង់ទេតែទំនងជាត្រូវសាបសូន្យបន្តិចម្តងៗជាពិសេសនៅស.វ.ទី៧ បើគេផ្អែកទៅលើសក្ខីភាព របស់ពុទ្ធសាសនិកចិនឈ្មោះយីស៊ីង ។ គេឃើញមានតែសិលាចារឹកមួយគត់និយាយពីព្រះភិក្ខុពីរអង្គ ។ ពុទ្ធសាសនាមហាយានចាប់ផ្តើមឃើញមានគេគោរពបូជាខ្លះៗហើយ ។

ក្នុងវិស័យស្ថាបត្យកម្ម ប្រាសាទច្រើនតែសង់ពីឥដ្ឋដាច់ៗ ពីគ្នាឬផ្តុំគ្នាជាក្រុម ។ ផ្តែនិងក្របក្លោងទ្វារគេធ្វើពីថ្មភក់ ។

រូបចម្លាក់បដិមានៅមានជាប់លក្ខណៈឥណ្ឌានៅឡើយ តែភាគច្រើនបានបង្ហាញក្បាច់រចនាបែបខ្មែរ ហើយមានរាងសង្ហាផង (ហរិហរប្រាសាទអណ្តែត) ។ ចម្លាក់តុបតែង (Sculpture décorative) មានសភាពល្អប្រណីតហើយថែមទាំងបានបន្តអានុភាពរបស់ខ្លួន រហូតមកដល់ក្នុងសម័យអង្គរទៀត ។



*ព្រះហរិហរ*
(ប្រាសាទអណ្តែតស.វទី៧) ស្នាដៃឯកមួយ
នៃសិល្បៈចម្លាក់បដិមាខ្មែរ

22 - B .P. Groslier, Angkor et le Cambodge au 16è siècle d´après les sources portugaises et espangnoles, PUF, Paris 1958

23- Jean Delvert, le Paysan Cambodgien, Mouton & Co La Haye, Paris 1961

24 - E. Aymonie, le Cambodge. t . III, Paris 1904.

25 - ភិក្ខុប៉ាងខាត់ -ប្រវត្តិពុទ្ធសាសនាប្រទេសខ្មែរ - ភ្នំពេញ ១៩៦១ ។

26 - Subhadradis Diskul. Art in Thailand, A brief history, Bangkok, 1971.

27 - Louis Finot, Les inscriptions de Mison ( n°II) ,BEFEO, IV.

28 - P -Pelliot, Le Founan, BEFEO.t.III.

29 - Louis Renou et Jean Filliozat . l´Inde classique . tomed , Hanoi , 1953 .

30 - Paul Pelliot, Mémoires sur les Coutumes du Cambodge de Tchéou Ta-Kouan, Paris, 1951.

31 - Tran Trong Kim, Viet Nam Su luoc , Saigon , 1964 .

32 - D Meunier, Histoire du Cambodge, PUF . Que sais - je ? Paris, 1961 .

33 - L. Finot, L´Inscription de Sdok Kak Thom, BEFEO, XV, 2.

34 - Philippe Stern, le temple - montagne Khmer. Le culte du linga et le devaraja, BEFEO, tome XXXIV, Fasc.2,1934 .

35 - Henri Stierlin, Un chef-d´oeuvre d´équilibre écologique, dans SOS. Angkor, Courrier de l´Unesco, Décembre, 1961.

36 - Georges Coedès, Pour mieux comprendre Angkor, Paris, 1947 .

37 - Mubin sheppard, Taman Indera, Oxford University Press, Kuala Lumpur Singapour, Lon don, Melbourne New York , 1972 .

38 - G. Coedès, Recueil des Inscriptions du Siam, 2è partie.

39 - M. Giteau, Histoire du Cambodge, Didier, Paris, 1957 .

40 - J . Imbert, Histoire des Institutions khmères, volume ll, Annales de la Faculté de Droit de Phnompenh , 1961 .